មជ្ឈមណ្ឌលឯកសារកម្ពុជា

TKI0763

**សម្ភាសន៍ជាមួយឈ្មោះ ម៉ៅ ឆោម ភេទប្រុស អាយុ៦២ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ កសិករ**

**សព្វថ្ងៃរស់នៅភូមិត្រយឹង ឃុំរាមអណ្តើក ស្រុកគីរីវង់ ខេត្តតាកែវ**

**ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ ជី ទេរិទ្ធ**

**០១:០៥:៥៤**

**៣៧ទំព័រ**

ឆោម : និយាយហ្នឹងអត់និយាយពីស្អីទេអី និយាយតែពីឆ្នាំ៧០តើអី?

ទេរិទ្ធ : អត់អីទេអ៊ំចាំខ្ញុំសួរពេលដែល

អ៊ំស្រី : ចាំគាត់សួរបានយើងឆ្លើយ ។

ទេរិទ្ធ : បាទ! ខ្ញុំសួរអ៊ំទៅអ៊ំនឹកឃើញប៉ុន្មាននិយាយប៉ុណ្ណឹងមក ភ្លេចថាភ្លេចអីអញ្ចឹងទៅ ។

ឆោម : វាមានដំណាក់៧០ ៧១ ៧៥ មានតាមដំណើរវាអញ្ចឹងណា ។

ទេរិទ្ធ : បាទ ចាំខ្ញុំសួរអ៊ំតាមដំណើរដែរអត់អីទេអ៊ំ បាទ អ៊ំអ៊ីអញ្ចឹងខ្ញុំៗមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាណាអ៊ំ មជ្ឈមណ្ឌលឯកសារកម្ពុជាកន្លែងបោះពុម្ពទស្សនាវដ្តីស្វែងរកការពិតនេះ អ៊ំពួកយើង គឺដើរចុះសួរប្រជាជនយើង អ្នកដែលធ្លាប់រស់នៅក្នុងសម័យខ្មែរក្រហមទាំងអស់ណាអ៊ំ ។ បាទ ហើយយើងចងក្រងប្រវត្តិរបស់គាត់ខ្លះយើងយកសរសេរជាអត្ថបទដាក់ក្នុងសៀវភៅទស្សនាវដ្តីនេះខ្លះ យើងយកទៅទុកស្រាវជ្រាវធ្វើសៀវភៅធ្វើអីណាអ៊ំ ។ ខ្លះទៀតទៅគឺយើងទុកឲ្យនិស្សិតបរទេស ដែលគេមកស្រុកខ្មែរយើងអញ្ចឹង គេចង់ដឹងពីរឿងស្រុកខ្មែរយើងអីអញ្ចឹងណាអ៊ំណា ។ បាទ អញ្ចឹងកាលណាយើងសម្ភាសន៍អីអញ្ចឹងទៅវានៅសល់រឿងហ្នឹងដែរអ៊ំណា វានៅសល់រាប់រយឆ្នាំអីទៀតអត់បាត់ទេសម្លេងអស់នេះនោះណាវានៅសល់បាទ ប៉ុន្តែបើយើងអត់កត់ទុកទៅក្រែងលោវាដូចថាវាបាត់បង់តាមហ្នឹងទៅ ទៅដែរតាមយើងណា បាទ សាមសិបឆ្នាំសែសិបឆ្នាំអីទៀតណាអ៊ំ ។ បាទ អ៊ំអញ្ចឹងថ្ងៃនេះខ្ញុំចង់មកសុំសម្ភាសន៍អ៊ំបន្តិចបានទេអ៊ំ?

ឆោម : មានអីបាន ។

ទេរិទ្ធ : បានអ៊ំណែ អ៊ំអញ្ចឹងដំបូងសូមស្គាល់ឈ្មោះអ៊ំសិន តើអ៊ំឈ្មោះអីគេអ៊ំ?

ឆោម : ខ្ញុំឈ្មោះ ម៉ៅ ឆោម ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ទេវិទ្ធ ៖ អ៊ំសព្វថ្ងៃអាយុប៉ុន្មានហើយអ៊ំ?

ឆោម ៖ សព្វថ្ងៃអាយុ៦២ឆ្នាំ ។

ទេវិទ្ធ ៖ រស់នៅភូមិអីគេអ៊ំសព្វថ្ងៃនេះ?

ឆោម ៖ ភូមិតាយឹង ឃុំរាំងអណ្តើក ស្រុកគិរីវង្ស ខេត្តតាកែវ ។

ទេវិទ្ធ ៖ អូ អ៊ំនិយាយច្បាស់ៗ បាទ អ៊ំអញ្ចឹងខ្ញុំអ៊ី សុំចាប់ផ្តើម អ៊ំកាលពីក្មេងបន្តិចអ៊ំមានស្រុក កំណើតនៅខាងណាវិញអ៊ំ ស្រុកកំណើតរបស់អ៊ំណា?

ឆោម ៖ កាលពីក្មេងខ្ញុំកើតនៅនឹងភូមិតាយឹងហ្នឹង ។

ទេវិទ្ធ ៖ អូ រស់នោហ្នឹងហ្មងអ៊ំណែ?

ឆោម ៖ បាទ!

ទេវិទ្ធ ៖ ឪពុកម្តាយរបស់អ៊ំស្រុកកំណើតនៅឯណាដែរ?

ឆោម ៖ ឪពុកម្តាយខ្ញុំគាត់ស្លាប់អស់ហើយ ។

ទេវិទ្ធ ៖ គាត់អ្នកស្រុកហ្នឹងដែរ?

ឆោម ៖ អ្នកស្រុកហ្នឹងដែរកំណើតហ្នឹងដែរ ។

ទេវិទ្ធ ៖ បាទ កាលអ៊ំនៅក្មេងឪពុកម្តាយអ៊ំគាត់ធ្វើអីគេអ៊ំ?

ឆោម ៖ ឪពុកម្តាយខ្ញុំគាត់ធ្វើតែស្រែធ្វើចម្ការរកស៊ីហ្នឹងណា អត់មានមុខរបរអីទេ ។

ទេវិទ្ធ ៖ គាត់ធ្វើស្រែចម្ការអ៊ំណែ?

ឆោម ៖ បាទ!

ទេវិទ្ធ ៖ ពេលដែលអ៊ំដឹងក្តីមករៀនបានថ្នាក់ប៉ុណ្ណាដែរអ៊ំ?

ឆោម ៖ ខ្ញុំពីដើមរៀនកាលនៅអាយុប្រាំពីរប្រាំបីឆ្នាំនោះខ្ញុំរៀននៅវត្តលោក រៀនបានពីដើមគេហៅ ថ្នាក់១២កម្មាដ្ឋានណា គេហៅកម្មាដ្ឋានណាថ្នាក់ពីដើមបរិអាទិណាថ្នាក់ពីដើម ប៉ុន្តែរៀន បានត្រឹមទី១២ទេទឹងប់ពីរហ្នឹងកម្មាដ្ឋានណា ចេះចប់ត្រឹមកម្មាដ្ឋានហ្នឹងខ្ញុំក៏ឈប់រៀនទៅ ។

ទេវិទ្ធ ៖ បាទ រៀននៅវត្តណាដែរអ៊ំ?

ឆោម ៖ រៀននៅវត្តព្រៃរំដេង ។

ទេវិទ្ធ ៖ ព្រៃរំដេងដូចធ្លាប់ឮអ៊ំ នៅខាងណាអញ្ចេះហ្នឹង?

ឆោម ៖ នៅត្បូងនោះនៅខាងត្បូង ។

ទេវិទ្ធ ៖ នៅខាងនោះណែ?

ឆោម ៖ ហ្នឹងហើយ ។

ទេវិទ្ធ :　　អូរឃុំព្រៃរំដេងបាទ　អូ　ខ្ញុំស្គាល់ហើយអ៊ី ។

នោម :　　រៀនវត្តមង្គលដងវត្តព្រៃរំដេងដងពីរវត្តម៉ែឪខ្ញុំគាត់ថាលោកកាចពេកដកទៅនោះ　ដល់ទៅនោះលោកនៅតែកាចដដែលហ្នឹង ។

ទេវិទ្ធ :　　លោកសុទ្ធតែកាច?

នោម :　　អ៊ឺ!

ទេវិទ្ធ :　　ចុះអ៊ីចេះធម៌អាទេ?　០០:០៣

នោម :　　ខ្ញុំធម៌ខ្ញុំចេះ ។

ទេវិទ្ធ :　　ចេះធម៌ដែរ?

នោម :　　ព្រោះខ្ញុំបួស១បានបីឆ្នាំ ។

ទេវិទ្ធ :　　បួសនៅវត្តហ្នឹង?

នោម :　　បួសនៅវត្តមង្គលបួសបីឆ្នាំ ។

ទេវិទ្ធ :　　បីឆ្នាំ?

នោម :　　ហ្នឹងហើយ ។

ទេវិទ្ធ :　　អ៊ីចាំឆ្នាំទេនៅឆ្នាំណាដែរ?

នោម :　　កាលខ្ញុំបួសឆ្នាំ៦០ប៉ុន្មានទេ　កាលបួសឆ្នាំ៦៧ ។

ទេវិទ្ធ :　　អ៊ីអាយុប៉ុន្មានហើយពេលហ្នឹង?

នោម :　　ពេលហ្នឹងអាយុ១៥ឆ្នាំ ។

ទេវិទ្ធ :　　អាយុ១៥ឆ្នាំ?

នោម :　　១៥ឆ្នាំ ។

ទេវិទ្ធ :　　តែពេលបួសហ្នឹងឈប់រៀនហើយ　ឬក៏បួសរៀនហ្នឹងហ្មង?

នោម :　　រៀនហើយហ្នឹងបានទៅបួស ។

ទេវិទ្ធ :　　អូ　ចុះអ៊ីចេះអានអក្សរទេរៀនបានមួយឆ្នាំអញ្ចឹង　អានដាច់ទេ?

នោម :　　អស្សរអានដាច់ ។

ទេវិទ្ធ :　　សព្វថ្ងៃអានដាច់ដែរ?

នោម :　　អានដាច់ស្អីក៏ចេះដែរតែចេះដល់បាលីហើយអត់តែបារាំង ។

ទេវិទ្ធ :　　ចេះបារាំងដែរកាលហ្នឹង?

នោម :　　អត់ចេះទេប៉ុនតែបាលីអីខ្មេចខ្ទីទាំងអស់ ។

ទេវិទ្ធ : ខ្ទេចខ្ទីអស់ហ្នឹង?

ឆោម : អ៊ឺ!

ទេវិទ្ធ : ចុះអញ្ចឹងប្អូនៗឆ្នាំ៦៧ ដល់ពេលបានបីឆ្នាំក្រោយមកអ៊ំសឹកហ្អ?

ឆោម : សឹក ។

ទេវិទ្ធ : ម៉េចបានសឹកកាលហ្នឹង?

ឆោម : ឆ្នាំ៧០រដ្ឋប្រហារ ។

ទេវិទ្ធ : បាទ!

ឆោម : រត់មករដ្ឋប្រហារហ្នឹងហ្នឹង សក់នៅរុយៗហ្នឹង ។

ទេវិទ្ធ : ដល់ពេលអ៊ំផ្សឹកហើយបានរដ្ឋប្រហារ ឬក៏រដ្ឋប្រហារហើយបានអ៊ំសឹក?

ឆោម : សឹកហើយៗហ្នឹងសឹកមកហ្នឹងរដ្ឋប្រហារហ្នឹងសក់នៅរុយៗនោះ ។

ទេវិទ្ធ : ផ្សឹកមករដ្ឋប្រហាហ្នឹង?

ឆោម : បាទ រដ្ឋប្រហារហ្នឹង អត់បានរកប្រពន្ធរកប្តីនឹងគេទេអាយុវាច្រើនដែរហើយ មើល១៥ បូកបីវាដប់ប្រាំបីឆ្នាំហើយ ។

ទេវិទ្ធ : អត់បានរកប្រពន្ធនឹងគេទេអ៊ំហ្អ?

ឆោម : អត់ទេរកឯណាបើរដ្ឋប្រហារហើយ ។

ទេវិទ្ធ : រដ្ឋប្រហារដល់ពេលរដ្ឋប្រហារទៅធ្វើម៉េចទៀតទៅអ៊ំកើតអី?

ឆោម : ដល់រដ្ឋប្រហារវាកាលជំនាន់នោះ ស្រែកប្រកាសសម្តេចសីហនុស្រែកហូប្រកាសថា បងប្អូនចូលព្រៃម៉ាកគីម៉ាកគា ។

ទេវិទ្ធ : ម៉ាកគីម៉ាកគា?

ឆោម : អ៊ឺ ដល់ពុអញ្ចឹងយើងមិនដឹងស្អីទេម៉ាកគីម៉ាកគាពុតែស្រែកពីលើមកថាបងប្អូនចូលព្រៃម៉ាកគីម៉ាកគា កាលពីផ្ទុះអាវុធឆ្នាំ៧០ លន់ នល់ ធ្វើរដ្ឋប្រហារហ្នឹងណា ។

ទេវិទ្ធ : បាទៗ ។

ឆោម : ខ្ញុំក៏មិនដឹងដែរម៉ាកគីម៉ាកគាឯណាទេ ។

ទេវិទ្ធ : ដល់ពេលពុហើយម៉េចទៀតទៅ?

ឆោម : ដល់ពុទៅថាអូ មានទ័ពខ្មែរយើងរំដោះមកហើយទ័ពរំដោះជាតិឈ្មោះមេគេ ចាន់ វ៉ាន់សាយ ។

ទេវិទ្ធ : ចាន់ វ៉ាន់សាយ?

ឆោម ៈ អ៊ី ឈ្មោះ ចាន់ វ៉ាន់សាយ មកនៅសាលាស្រុកយើងគិរីវង្សហ្នឹងណា ។

ទេវិទ្ធ ៈ បាទ!

ឆោម ៈ ហើយដល់ទៅខ្ញុំទៅមិនទាន់ៗគេចុះឈ្មោះទៅបានទៅចូលជាមួយយៀកកុងទៅ ចូលជាមួយយួនទៅ យួនហ្នឹងយៀកកុងហ្នឹងក៏សត្រូវជាមួយ លន់ នល់ ជាមួយខៀវគីដែរជំនាន់ហ្នឹងដឹងទេ?

ទេវិទ្ធ ៈ បាទៗអ៊ឺបាទ ។

ឆោម ៈ វាមានពីរផ្នែកដូចខ្មែរយើងដែរណា ។

ទេវិទ្ធ ៈ បាទ!

ឆោម ៈ ហ្នឹងហើយ ។

ទេវិទ្ធ ៈ ចុះអ៊ីដល់ពេលអ៊ី ម៉េចបានជាអ៊ឺចូលខៀវគី អ៊ី យៀកកុងទៅវិញអ៊ឺ? ព្រោះខាងសម្ដេចអំពាវនាវឲ្យយើងចូលតស៊ូ?

ឆោម ៈ វាអង្គការវាដូចគ្នាទេតែដល់តែអង្គការនេះដូចថាវាគេឡើងទៅហួសទៅ គេទៅរើកំពង់ស្ពឺអស់ហើយបានថាឲ្យចូលជាមួយហ្នឹងទៅវាអង្គការដូចគ្នាហ្នឹង គ្រាន់តែគេឈពីរ ។

ទេវិទ្ធ ៈ អញ្ចឹង បាទ ។

ឆោម ៈ ព្រោះជំនាន់នោះមានអង្គការខ្មែរមួយអង្គការយួនមួយដឹងទេ?

ទេវិទ្ធ ៈ អញ្ចឹង?

ឆោម ៈ យួនខាងហ្នឹងវាជំនាន់ហ្នឹងអញ្ចឹងបានយៀកកុងហ្នឹងក៏វាសត្រូវជាមួយ លន់ នល់ ជាមួយខៀវគីដែរ ហើយកាលយើងនៅហ្នឹងយើងមិនរើជាមួយ លន់ នល់ ។

ទេវិទ្ធ ៈ បាទ!

ឆោម ៈ ហ្នឹងហើយ ប្រាប់អូនឯងអញ្ចឹងឲ្យដឹង ។

ទេវិទ្ធ ៈ អញ្ចឹងក៏ចូលតាមយៀកកុងទៅ អ៊ឺចូលដោយចិត្តឯង ឬក៏មានអ្នកនាំ?

ឆោម ៈ ចូលនាំទៅមិនមែនមានតែខ្ញុំម្នាក់ឯងឯណានៅមួយកងរយវាខ្មែរដប់ប្រាំនាក់ ។

ទេវិទ្ធ ៈ វៀតណាម៧៥?

ឆោម ៈ មួយកងរយវាណា ពីរកងហា ។

ទេវិទ្ធ ៈ ពីកងហា?

ឆោម ៈ ប៉ុនខ្មែរយើង១៥នាក់ ។

ទេវិទ្ធ ៈ ខ្មែរយើងតែ១៥នាក់ អញ្ចឹងក្រៅពីហ្នឹងសុទ្ធតែវៀតណាម?

ឆោម ៖ ក្រៅពីហ្នឹងសុទ្ធតែវៀតណាម ។

ទេវិទ្ធ ៖ ចេះនិយាយវៀតណាមដែរអ៊ំ?

ឆោម ៖ រៀនចេះខ្លះៗដែរវានិយាយថាផ្លូវឯណាឯណី និយាយបន្តិចបន្តួចៗហ្នឹងចេះហើយ ឌីចូវ ឌីចឺយ ឌីណា ឌីទួយ អីទៅរៀនជាមួយវាហ្នឹង ។

ទេវិទ្ធ ៖ ចេះនិយាយបានខ្លះដែរឥលូវហ្នឹងអ៊ំ?

ឆោម ៖ វាបានខ្លះប៉ុនតែវាមិនបានខ្ទេចខ្ទីទេ ។

ទេវិទ្ធ ៖ អូ បាទ ចុះយៀកកុងហ្នឹងចូលទៅឆ្នាំណាទៀតអ៊ំ? ចូលនៅកន្លែងណា?

ឆោម ៖ ចូលនៅផ្សាគិរីវង្សហ្នឹង ។

ទេវិទ្ធ ៖ ចូលក្នុងផ្សារគិរីវង្សណែ?

ឆោម ៖ ហ្នឹងហើយវាមក ។

ទេវិទ្ធ ៖ ហើយកាលហ្នឹងប្រធានខាងកងវរយហ្នឹងពីណាគេ អ៊ំស្គាល់ឈ្មោះទេ?

ឆោម ៖ ប្រធានកងវរយឈ្មោះគេអាហ្នឹងប្រធានខាងឃុំនណា ឈ្មោះគេ ណាំខូ ។

ទេវិទ្ធ ៖ ណាំខូ?

ឆោម ៖ ណាំខូ ហើយកងហាៗពីរកងហាមួយឈ្មោះ លឿង មួយឈ្មោះ ឡាយ ។

ទេវិទ្ធ ៖ ចុះសុទ្ធតែវៀតណាមអញ្ចឹងគេចេះខ្មែរទេវៀតណាមអស់ហ្នឹង?

ឆោម ៖ វៀតណាមមានថៃបកគេ ។

ទេវិទ្ធ ៖ អូ គេមានអ្នកបកប្រែ?

ឆោម ៖ អ៊ឺ គេមានថៃបកហើយយើងនិយាយគ្នានិយាយអីមកអ្នកគ្រប់គ្រងយើងមានថៃបកវា ។

ទេវិទ្ធ ៖ ចុះខ្មែរយើង១៥នាក់ផ្សេងទៀតហ្នឹងអ្នកណាខ្លះ ស្គាល់ឈ្មោះទេអ៊ំ?

ឆោម ៖ ខ្ញុំចាំមិនគ្រប់ទេឥលូវវាភ្លេចនៅខ្លះ ។

ទេវិទ្ធ ៖ នៅខ្លះហ្នឹងពីណាខ្លះដែរចាំទេអ៊ំ?

ឆោម ៖ មួយឈ្មោះអាង៉ាន់ ពីរឈ្មោះអាខាវ បីឈ្មោះអាហន បួនឈ្មោះអាសាន ប្រាំអាហឿង ភ្លេចអស់ហើយ១៥នាក់ប៉ុនខ្ញុំភ្លេចអស់ហើយចាំមិនអស់ទេ ។

ទេវិទ្ធ ៖ ចុះអ្នកទាំងអស់ហ្នឹងសព្វថ្ងៃហ្នឹងនៅឯណាដែរអ៊ំ?

ឆោម ៖ អ្នកទាំងអស់ហ្នឹងនៅ ។

ទេវិទ្ធ ៖ នៅរស់ទេ?

ឆោម ៖ នៅរស់ ។

ទេវិទ្ធ : ហូ! ចុះពួកគាត់ទាំងអស់ហ្នឹងនៅណាខ្លះទៅ?

ឆោម : អាមួយនោះនៅជិតគ្នាអាមួយនៅយ៉ាម៉ោងនោះ មួយនៅយ៉ាបិននោះ ។

ទេវិទ្ធ : ចុះអ្នកនៅជិតគ្នានេះឈ្មោះអីគេដែរអ៊ំ?

ឆោម : ឈ្មោះង៉ាន់ ។

ទេវិទ្ធ : ឈ្មោះង៉ាន់?

ឆោម : អ៊ឺ ជិតគ្នាឈ្មោះង៉ាន់ ធ្លាប់នៅជាមួយយៀកកុងនៅជមួយគ្នាណា ។

ទេវិទ្ធ : បាទៗ គាត់នៅភូមិណាដែរអ៊ំ?

ឆោម : នៅភូមិហ្នឹងដែរភូមិតាយឹងហ្នឹងដែរ ។

ទេវិទ្ធ : តាយឹងដែរ?

ឆោម : ហ្នឹងហើយ ។

ទេវិទ្ធ : បាទ ចុះអ៊ុំ អ៊ំដល់ពេលចូលទៅអញ្ចឹងមេកងហាកងរយសុទ្ធតែវៀតណាមទាំងអស់?

ឆោម : សុទ្ធតែវៀតណាម ។

ទេវិទ្ធ : ចុះដល់ពេលខ្មែរយើងទៅធ្វើកូនចៅគេ?

ឆោម : កូនចៅគេ ។

ទេវិទ្ធ : ដល់ពេលចូលទៅភ្លាមទៅគេថាម៉េចខ្លះទៅ ចង់និយាយ?

ឆោម : គ្មានអីគេគេបំពាក់អាវុធបំពាក់អីទៅ ប៉ុនខ្ញុំមិនមែនខាងកងវ៉ៃទេណាទៅនៅខាងកងដឹកជញ្ជូន ។

ទេវិទ្ធ : អ៊ំហ្នឹងខាងកងដឹកជញ្ជូន?

ឆោម : ខាងកងដឹកជញ្ជូនខាងលីគ្រាប់គ្រាប់សែងគ្រាប់សែងរបួសអីហ្នឹង ។

ទេវិទ្ធ : អូ!

ឆោម : គ្មានបានវ៉ៃនឹងគេទេបានតែប៉ុណ្ណឹង ។

ទេវិទ្ធ : បាទ ចុះគេឲ្យពាក់កាំភ្លើងហ្នឹងកាំភ្លើងអីគេ?

ឆោម : កាំភ្លើងអាកា ។

ទេវិទ្ធ : អាកា៤៧ហ្នឹង?

ឆោម : ៤៧ ។

ទេវិទ្ធ : របស់អីៗអ៊ំ?

ឆោម : របស់ជប៉ុន ។

ទេវិទ្ធ :	របស់រុស្ស៊ី ឬរបស់ចិន?

ឆោម :	អាហ្នឹងវាមានកាំបិត ។

ទេវិទ្ធ :	អាហ្នឹងមានកាំបិត?

ឆោម :	អ៊ឺ មានកាំបិត ។

ទេវិទ្ធ :	របស់រុស្ស៊ីហើយអញ្ចឹងនោះ ។

ឆោម :	អ៊ឺ មានកាំបិតអាហ្នឹង ។

ទេវិទ្ធ :	ព្រោះវារបស់វៀតណាមប្រហែលជាយកមកពីរុស្ស៊ី ចុះខោអាវគេមានឲ្យខោអាវអីទេ?

ឆោម :	ខោអាវគេបើកឲ្យអាខោអាវហាណូយៗគេហ្នុង មួយកំផ្លៅ ។

ទេវិទ្ធ :	ពណ៌វាយ៉ាងម៉េចទៅអ៊ឺ?

ឆោម :	ពណ៌ស្លឹកឈើសម្បុរស្លឹកៗឈើ ។

ទេវិទ្ធ :	តែក្រឡេក្រឡាទេ?

ឆោម :	អ៊ឺៗ ក្រឡេក្រឡាហ្នឹងហើយ ។

ទេវិទ្ធ :	ខោអាវដូចខោអាវប៉ាវ៉ាហ្នឹង?

ឆោម :	អ៊ឺ ដូចប៉ាវ៉ាអញ្ចឹង ។

ទេវិទ្ធ :	អូ ពាក់ខោអាវហ្នឹងទាំងអស់គ្នា?

ឆោម :	ពាក់ខោអាវហ្នឹងទាំងអស់គ្នា ។

ទេវិទ្ធ :	ដល់ពេលចូល ដល់អញ្ចឹងគ្រាន់តែថ្ងៃអ៊ឺចូលទៅផ្សារគិរីវង្សហ្នឹងគេឲ្យអាវុធពាក់ហ្នុង?

ឆោម :	កាលហ្នឹងទៅដល់កន្លែងវាៗឲ្យអាវុធហ្នុង ប្រគល់អាវុធឲ្យហ្នុង ។

ទេវិទ្ធ :	ទៅដល់ផ្សារគិរីវង្សហ្នឹង?

ឆោម :	ផ្សារគិរីវង្សហ្នឹងវាបញ្ជូនទៅកន្លែងវាមេងវានៅលើភ្នំនេះ នៅលើភ្នំអាងខ្មៅយើងនេះ ។

ទេវិទ្ធ :	ភ្នំអាងខ្មៅ?

ឆោម :	នេះនៅនេះ ។

ទេវិទ្ធ :	អូ អញ្ចឹងយើងចូលនៅផ្សារគិរីវង្ស ហើយបន្ទាប់មកវាបញ្ជូនឲ្យទៅជួបមេនៅភ្នំអាងខ្មៅ?

ឆោម :	អ៊ឺ នៅលើភ្នំនេះ ។

ទេវិទ្ធ :	ភ្នំអាងខ្មៅ ហើយនៅលើភ្នំហ្នឹងមានពួកវៀតណាមច្រើនទេ?

ឆោម :	វៀតណាមនៅពេញទាំងអស់ ។

ទេវិទ្ធ :	សុទ្ធវៀតណាម?

ឆោម : នៅតាមអូរនៅពេញទាំងអស់ ។

ទេវិទ្ធ : មានខ្មែរទេ?

ឆោម : គ្មានទេសុទ្ធតែវៀតណាមមានស្រីមានប្រុសអាញ៉ូអាញ៉ៃ ។

ទេវិទ្ធ : ផាប់ប៉ាដោយហើយចុះនៅហ្នឹងគេបោះទីតាំងយូនៅអ៊ំវៀតណាមអស់ហ្នឹង?

ឆោម : វាបោះជំនាន់ហ្នឹងដូចថាវាមកវាមានដូចថាវាមកខាងស្រុកគិរីវង្សយើងហ្នឹង មកហ្នឹងដូចវាចាប់គ្នាវាមកអញ្ចឹងណា ។

ទេវិទ្ធ : បាទ អត់ដឹងវាមកតាំងពីឆ្នាំណាទេ?

ឆោម : មិនដឹពីឆ្នាំណាទេប៉ុនវាមកមានកន្លែងគេធ្វើស្អាតណាស់ ។

ទេវិទ្ធ : វាជាទីតាំងទ័ពហ្នឹងហើយណែ?

ឆោម : ទីតាំងវាហ្នឹង ។

ទេវិទ្ធ : មានរណ្ដៅមានអី?

ឆោម : មានរណ្ដៅត្រង់សេមានមុងមានអីអង្រឹងមានអីដេក មានពេទ្យមានអីគ្រប់ទាំងអស់អត់ខ្វះទេ អត់ចេះខ្វះអីទេ ទឹកដឹកចុះទឹកអូរដឹកតាមអូរនោះៗ ។

ទេវិទ្ធ : បើអ៊ំ ប្រហែលជាមនុស្សប៉ុន្មាននាក់ដែរនៅភ្នំអាងខ្មៅហ្នឹង?

ឆោម : ខ្ញុំ?

ទេវិទ្ធ : អត់ទេទាំងអស់គ្នាណាទាំងវៀតណាមទាំងទ័ពយើងទាំងអីណា?

ឆោម : កងទ័ពយើងជំនាន់ហ្នឹងខ្ញុំដឹងតែក្នុងកងខ្ញុំហ្នឹង ខ្ញុំដឹងតែគ្នាខ្ញុំហ្នឹង ។

ទេវិទ្ធ : ប៉ុន្តែនៅពេលអ៊ំទៅដល់ភ្នំអាងខ្មៅហ្នឹងឃើញ បើអ៊ំប៉ាន់ស្មានចំនួនមនុស្សណាមនុស្សប្រហែលជាប៉ុន្មាននាក់ដែរមើលទៅអ៊ំឃើញពេលហ្នឹង?

ឆោម : វាចេញចូលៗវាច្រើនណាស់ជូនទៅមកជូនអាឡើងមកអាក្រោមមក អាទៅៗអាពួកវៃវាទៅដេរ្សងទៅវាឡើងទៅវៃទៅលើទៀតទៅ ទៅវៃនៅកំពង់ស្ពឺបន្ទាយកោះខ្លោរនោះ ។

ទេវិទ្ធ : ច្រើនមែនទែន?

ឆោម : អ៊ឺ ហ្នឹងហើយវាវៃវាមាំណាស់កាលហ្នឹងវាទៅវៃដល់ខ្លោរនោះមិនងាយបែកឯណា បន្ទាយកោះខ្លោរឹងមាំណាស់ណានៅខេត្តកំពង់ស្ពឺហ្នឹង ។

ទេវិទ្ធ : បាទ ចុះនៅពេលដែល អ៊ំទៅដល់ភ្នំអាងខ្មៅហ្នឹងជួបមេហើយគេឲ្យកាំភ្លើងពាក់?

ឆោម : បាទ!

ទេវិទ្ធ : ហើយនៅហ្នឹងគោមានបង្រៀនយើងបាញ់អីៗទេ?

ឆោម : គេបង្រៀនហាត់ហូយហាត់ហ្នឹងហើយណា ហាត់លូនហាត់ប្រាណអីណាគ្មានទេមួយថ្ងៃៗលូនរបកដៃអស់ហើយ ។

ទេវិទ្ធ : ហាត់ប៉ុន្មានដែរ រយៈពេលប៉ុន្មានដែរ?

ឆោម : ហាត់ហ្នឹងវារយៈប្រហែលមួយខែជាង ។

ទេវិទ្ធ : តែជាងមួយខែទេអញ្ចឹងណែ?

ឆោម : អ៊ឺ ទាំងហាត់ប្រាណហាត់បាញ់ហាត់លូនណែហាត់ដាក់កុងដាក់អីហ្នឹងណា ។

ទេវិទ្ធ : នៅលើភ្នំហ្នឹងទាំងអស់?

ឆោម : នៅលើភ្នំទាំងអស់ហាត់នៅលើភ្នំ ។

ទេវិទ្ធ : ចុះមានលន់ នល់ អីមកវៃលើភ្នំហ្នឹងទេ?

ឆោម : លន់ នល់ អត់មានទេ លន់ នល់ បន្ទាយគេមាននៅទម្លាប់ ។

ទេវិទ្ធ : អញ្ចឹងណែ?

ឆោម : ហើយនឹងគិរីវង្ស ហើយយើងនៅលើភ្នំក្បែរៗហ្នឹង មានតែកប៉ាល់ហោះ ។

ទេវិទ្ធ : កប៉ាល់ហោះមក?

ឆោម : កប៉ាល់ហោះវាមកយកការរាល់ថ្ងៃខាងលើហ្នឹង ។

ទេវិទ្ធ : ចុះមានដើមឈើមានព្រៃអីទេអ៊ំ ឬក៏នៅវាលហ្នង?

ឆោម : ព្រៃ ។

ទេវិទ្ធ : អូ នៅក្នុងព្រៃណែ?

ឆោម : ហើយដល់ពេលដាំស្លអីវាអត់ឲ្យមានផ្សែងទេវាបក់វាអត់ឲ្យផ្សែងទេ ។

ទេវិទ្ធ : បក់ម៉េចទៅអ៊ំ?

ឆោម : វាបក់មិនឲ្យផ្សែងឡើងខ្លាចអាកាប៉ាល់ហោះវាយកការបានហ្នឹង ។

ទេវិទ្ធ : ចុះបក់ម៉េចទៅអ៊ំ បើយើងដាំស្លមានផ្សែង?

ឆោម : វាបក់កុំឲ្យវាទៅលើ ។

ទេវិទ្ធ : អូ បក់អញ្ចេះ ។

ឆោម : អ៊ឺ បក់វាមិនដះទៅលើ បើយើងមិនទេះវាខ្ទូលទៅលើហើយឡានហោះនៅពីលើ ហ្នឹងហើយ ។

ទេវិទ្ធ : ចុះអ៊ំនៅហាត់ហ្នឹង ចាំមើលរដ្ឋប្រហារថ្ងៃទី១៨មិនាអ៊ំណែ?

ឆោម : ១៧?

ទេរិទ្ធ ៈ ១៨មិនា?

ឆោម ៈ អ៊ឺ!

ទេរិទ្ធ ៈ ឆ្នាំ៧០?

ឆោម ៈ ឆ្នាំ៧០ ។

ទេរិទ្ធ ៈ ចុះក្រោយហ្នឹងប៉ុន្មានថ្ងៃគេមកប្រកាសឡានហោះហ្នឹងមកឲ្យចូលព្រៃម៉ាក់គិម៉ាក់គាហ្នឹង?

ឆោម ៈ ផ្ទុះអាវុធហ្នឹងហ្នង ។

ទេរិទ្ធ ៈ ផ្ទុះភ្លាមថ្ងៃហ្នឹង?

ឆោម ៈ អ៊ឺ គ្រាន់តែផ្ទុះអាវុធឡានហោះស្រែកហ្នង ។

ទេរិទ្ធ ៈ ចុះអ៊ំចូលភ្លាម?

ឆោម ៈ ចូលភ្លាម ចុះមិនដឹងនៅធ្វើស្អីកម្លោះៗព្រួតគ្នាទៅហើយដល់ទៅៗមិនទាន់គេ គេចូលជាមួយទ័ពខ្មែរឡើងទៅលើទៅអស់ទៅ គេថានៅជាមួយទ័ពយួនក៏បានដែរនៅទៅ ។

ទេរិទ្ធ ៈ អ្នកណាអ្នកបបួលទៅអ៊ំ?

ឆោម ៈ ទៅដោយចិត្តឯងហ្នងអត់ដឹងនៅធ្វើស្អីទៅធ្វើទ័ពទៅ ។

ទេរិទ្ធ ៈ បាទ! ទៅទាំងអស់គ្នាហ្នឹងហ្នង?

ឆោម ៈ ទៅទាំងអស់គ្នាបបួលគ្នាក្នុងភូមិ ។

ទេរិទ្ធ ៈ ១៥នាក់សុទ្ធតែកម្លោះៗ?

ឆោម ៈ ទៅកម្លោះៗហ្នឹង ។

ទេរិទ្ធ ៈ មានស្រីៗទេ?

ឆោម ៈ គ្មានទេ ។

ទេរិទ្ធ ៈ ប្រុសទាំងអស់?

ឆោម ៈ សុទ្ធតែប្រុសទាំងអស់ ។

ទេរិទ្ធ ៈ អូ ចុះដល់ពេលចូលទៅអ៊ុំ ចូលទៅលើព្រៃនៅលើហ្នឹងក្រោយមួយខែក្រោយហាត់ទាហានមួយខែមកទៅណាទៀតអ៊ំ?

ឆោម ៈ មិនទៅណាទេវាគ្មានទៅណាមានតែបញ្ជូនអញ្ចឹងសែងរបួសស្ពាយចង់ផាប់ អាខ្លះបាញ់ផេះមួយចំហៀងខ្លួននៅតែរស់ពូកែដល់ហើយ ។

ទេរិទ្ធ ៈ គេបាញ់នៅឯណា?

ឆោម ៈ បាញ់នៅក្រោមយកមកពីក្រោមបញ្ជូនមកពីក្រោមមក ។

ទេវិទ្ធ ៖ អញ្ចឹងអ៊ំអត់ទៅទេអ៊ំនៅលើភ្នំហ្នឹងហើយជួយសែងគ្នា?

ឆោម ៖ នៅលើភ្នំប៉ុនខ្ញុំទៅយកឯទល់ដែននោះ ទៅយកឯវៀតណាមនោះទទួលពីនោះមកទៀត ណាវាបន្តមកទៀតវាវៃនៅក្រោមនោះ ។

ទេវិទ្ធ ៖ ក្រោមខាងណាវិញ?

ឆោម ៖ ក្រោមស្រុកយួនហ្នឹងវាវៃនៅហ្នឹងអាយៀកកុង ហើយយួនវៃគ្នាទៅ ។

ទេវិទ្ធ ៖ អូ វៀតណាមខាងជើង និងខាងត្បូងខៀវគី និងយៀកកុង?

ឆោម ៖ ហ្នឹងហើយៗ អ៊ុំហ្នឹងហើយ ។

ទេវិទ្ធ ៖ អូ អញ្ចឹងអ៊ំទៅព្យាបាលវៀតណាមវិញ?

ឆោម ៖ អ៊ុំ អត់ទេវាទៅអញ្ចឹងទៅដល់នេះទៅសែងគេអ្នកនេះយួនហ្នឹងស្អុយចង់ងាប់ហើយ ។

ទេវិទ្ធ ៖ ទៅសែងអញ្ចឹងអ៊ំទៅសែងយកដល់វៀតណាមមក?

ឆោម ៖ ទទួលគ្នាមកគេសែងយកមកអញ្ចឹងយើទទួលបន្តៗគ្នាមក ប៉ុនវាមានកន្លែងមូលដ្ឋានវានៅ កន្លែងលើភ្នំយើងនេះប្រធានពេទ្យទាហាននេះ សែងយកមកដាក់មន្ទីពេទ្យហ្នឹង ។

ទេវិទ្ធ ៖ អូ មានពេទ្យលើភ្នំហ្នឹង?

ឆោម ៖ ហ្នឹងហើយភ្នំហ្នឹងទីតាំងពេទ្យវាហ្នឹង ។

ទេវិទ្ធ ៖ ចុះអ៊ំសែងម្តងប្រហែលប៉ុន្មានគីឡូដី?

ឆោម ៖ ប្រហែលចូល១៥គីឡូ ។

ទេវិទ្ធ ៖ ១៥គីឡូទៅមក៣០គីឡូហើយអញ្ចឹង?

ឆោម ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ ដើរៗរហូត?

ឆោម ៖ ដើរហ្នឹងសែងដើររហូត ។

ទេវិទ្ធ ៖ ងាប់បណ្តោយ ។

ឆោម ៖ ហើយស្អុយអ្នកខ្លះស្អុយហើយនៅរស់ ។

ទេវិទ្ធ ៖ នៅរស់ទៀត?

ឆោម ៖ អ្នកខ្លះធ្លាយមកអញ្ចេះហើយៗនៅតែរស់ស្រែកអូយៗនៅលើអង្រឹងហ្នឹង ប្រាប់ថាកុំឲ្យ ស្រែកៗនៅតែនេះទៀតក្តៅចិត្តទម្លាក់ ចុះខ្លាច ។

ទេវិទ្ធ ៖ ខ្លាចដែរ?

ឆោម ៖ ខ្លាចទាហាន លន់ នល់ លន់ នល់ វាមកត្រៀមណា ។

ទេវិទ្ធ ៖ បាទ!

ឆោម ៖ គ្រៀមចាំនៅយើងនេះភ្នំក្រពើនេះ បាញ់គ្នានៅហ្នឹង ។

ទេវិទ្ធ ៖ ចុះពេលទៅសែងអញ្ចឹងមានស្ពាយកាំភ្លើងទៅអត់?

ឆោម ៖ កាំភ្លើងមាន ។

ទេវិទ្ធ ៖ ស្ពាយទាំងកាំភ្លើងទៅទៀត?

ឆោម ៖ ស្ពាយកាំភ្លើងណាវាស្រែក ។

ទេវិទ្ធ ៖ ប៉ុន្មាននាក់សែងទាហានរបួសម្នាក់?

ឆោម ៖ ពីរនាក់ ។

ទេវិទ្ធ ៖ ១៥គីឡូដើរប៉ុន្មានថ្ងៃដែរ?

ឆោម ៖ ដើរយប់មានដែលដើថ្ងៃឯណា យប់ថ្ងៃអាណាហានអត់ហានទេ យប់ដើរតែយប់ទេថ្ងៃអត់ហាន?

ទេវិទ្ធ ៖ ចុះអ៊ំទៅសែងរយៈពេលទៅមកៗហ្នឹងរយៈពេលប៉ុន្មានដែរ ធ្វើការនៅពេទ្យហ្នឹងដល់ប៉ុន្មានដែរ? ដល់ឆ្នាំណា?

ឆោម ៖ ធ្វើជាមួយវាបានមួយឆ្នាំ មួយឆ្នាំបានគេថាមានខ្មែរយើងអង្គការខ្មែរយើងចុះមកណាថាបើអញ្ចឹងអង្គការខ្មែរយើងចុះមកហើយយើងទៅជាមួយអង្គការខ្មែរវិញទៅ ។

អ៊ំស្រី ៖ អាអូនមុខដូចកូនពូនេះកូនពូដែងកូនពូអឿន ។

ទេវិទ្ធ ៖ ខ្ញុំនេះហ្នឹង?

អ៊ំស្រី ៖ អ៊ឺ!

ទេវិទ្ធ ៖ អត់ទេខ្ញុំនៅភ្នំពេញហ្នឹង ។

ឆោម ៖ អង្គការខ្មែរយើងមកពីដើមឈ្មោះតាណែម មកកាន់ស្រុកគិរីវង្សនេះណាអង្គការឈ្មោះតាណែម ។

ទេវិទ្ធ ៖ បោះទីតាំងនៅឯណាវិញ?

ឆោម ៖ គាត់នៅឯសំរោងយើងនេះ ។

ទេវិទ្ធ ៖ សំរោងអីគេ?

ឆោម ៖ ហៅភូមិវត្តចំបក់មន្ទីគាត់នៅហ្នឹង មន្ទីអង្គការខ្មែរណា ។

ទេវិទ្ធ ៖ នៅស្រុកីអាហ្នឹង?

ឆោម ៖ ស្រុកគិរីវង្សដដែល ឃុំគោកព្រិច ។

ទេវិទ្ធ ៖ ឃុំគោកព្រិចវិញ អូស្គាល់ហើយៗ ។

ឆោម ៖ អ៊ឺ

ទេវិទ្ធ ៖ ចុះអ៊ីបន្ទាប់ពីនៅហ្នឹងមួយឆ្នាំហើយមកធ្វើការឲ្យខ្មែរវិញហើយហ្ន ទៅនៅគោកព្រិច?

ឆោម ៖ ចាំមើលខ្ញុំនិយាយតាណែមហ្នឹងគាត់ប្រធានយោធា ហើយនឹងតាទុំនេះគាត់ប្រធានមន្ទីស្រុកហ្នឹងហ្នង គាត់អ្នកកាន់ខាងយោធាតាណែមហ្នឹង គាត់ដើរប្រកាសថាអ្នកណានៅជាមួយវៀតណាមឲ្យមកខ្មែរយើងវិញ ចូលជាមួយអង្គការខ្មែរវិញណា ។ ហើយអញ្ចឹងបានបបួលគ្នា១៥នាក់ហ្នឹងមក មួយថ្ងៃនោះគេហៅប្រជុំយួនគេហៅប្រជុំណា ប្រជុំហ្នឹងយៀកកុងគេហៅប្រជុំគេថាឥលូវបងប្អូនទៅអង្គការខ្មែរវិញទៅចុះ មួយៗគេទំនាស់គ្រប់គ្នាថាបើទៅកាំភ្លើងគេអត់ឲ្យទេ គេដកកាំភ្លើងចេញអស់ឲ្យមកតែខ្លួនដកកាំភ្លើងយកវិញអស់ហើយ គេឲ្យមកតែខ្លួន ។

ទេវិទ្ធ ៖ យៀកកុងដកកាំភ្លើងយកអស់?

ឆោម ៖ យកអស់គេឲ្យមកតែខ្លួន ។

ទេវិទ្ធ ៖ ចុះខោអាវទាហានគេយកដែរ?

ឆោម ៖ មិនទេខោអាវវាអត់ទេមួកអីគេមិនយកទេ គេយកតែកាំភ្លើង ។

ទេវិទ្ធ ៖ អញ្ចឹងយើងក៏ដើរវិញមក?

ឆោម ៖ បាទ ដើរមកចូលនៅជាមួយអង្គការខ្មែរអញ្ចឹងទៅ នៅហ្នឹងយើងបានធ្វើទ័ព ។

ទេវិទ្ធ ៖ នៅកោះព្រិចហ្នឹង?

ឆោម ៖ អ៊ឺ គេឲ្យធ្វើទ័ពស្រុក ។

ទេវិទ្ធ ៖ ធ្វើទ័ពស្រុក?

ឆោម ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ បន្ទាប់មកទៀតធ្វើម៉េចទៀតទៅ?

ឆោម ៖ ធ្វើទ័ពស្រុកគេបញ្ជូនទៅតមបន់គេបញ្ជូនទៅខេត្ត បញ្ជូនទៅខេត្តខ្ញុំមិនទៅ ។

ទេវិទ្ធ ៖ ចុហវ៉ៃអ៊ីមានវ៉ៃជាមួយលន់ នល់ ទេ?

ឆោម ៖ ទៅវ៉ៃនៅតាកែវបញ្ជូនឲ្យទៅវ៉ៃនៅតាកែវនេះតែខ្ញុំរត់ ។

ទេវិទ្ធ ៖ គេថាម៉េចទៅ ចុះទាហានគេថាម៉េចទៅដល់ពេលយើងរត់អញ្ចឹងមិនដាក់ពិន័យយើង?

ឆោម ៖ មានអ្នកស្គាល់ដែរអាមួយបបថមអាមួយមិនបបថមគេទៅសុំប្រធានមន្ទី ដល់ពេលគេទៅៗដែរទៅ អ៊ឺ មានអ្នកបបថមមានអ្នកមិនបបថម ។ ប្រធានយោធាវាបបថម ហើយតាទុំ គាត់

ថាហេនៅទៅខ្ញុំថានៅធ្វើស្អី គេថានៅធ្វើស្រែធ្វើអីដល់អញ្ចឹងខ្ញុំគេបែកចេញពីទ័ពហើយ ដកចេញពីទ័ពរួចហើយគេធ្វើមានសេដ្ឋកិច្ចគេមានគោ មានប្រធានសេដ្ឋកិច្ចសេដ្ឋអីអញ្ចឹងទៅ ធ្វើស្រែធម្មតាវិញទៅ ។

ទេវិទ្ធ : អញ្ចឹងអ៊ំក៏ចូលមកខាងសេដ្ឋកិច្ចវិញមក?

ឆោម : អ៊ឺ! ចូលមកសេដ្ឋកិច្ចវិញមក ។

ទេវិទ្ធ : ឆ្នាំណាដែរមើលទៅពេលហ្នឹង ពេលចូលសេដ្ឋកិច្ចហ្នឹងឆ្នាំណា?

ឆោម : កាលហ្នឹងឆ្នាំ៧៣ ។

ទេវិទ្ធ : ៧៣ហើយ?

ឆោម : ៧៣ ។

ទេវិទ្ធ : ពេលអ៊ំធ្វើសេដ្ឋកិច្ចហ្នឹងធ្វើអីខ្លះទៅ? ធ្វើនៅខាងណាវិញទីតាំងអ៊ំធ្វើនៅណា?

ឆោម : ទីតាំងខ្ញុំនៅជីស្រុកគិរីវង្សហ្នឹងរួចនៅនេះរួចលើកទៅនោះទៅនេះទៅនោះទៅ ទីណាមាន ស្រែរួមធ្វើទៅ ។

ទេវិទ្ធ : គេនៅវៃគ្នាជាមួយ លន់ នល់ នៅលើយទេ?

ឆោម : នៅវៃជាមួយ លន់ នល់ ដដែល ។

ទេវិទ្ធ : បាទ ចុះធ្វើអីខ្លះទៅអ៊ំការងារប្រចាំថ្ងៃ?

ឆោម : ការងារប្រចាំថ្ងៃធ្វើស្រែ គេឲ្យភ្ជួរធម្មតាយើងហ្នឹងភ្ជួរដាំដំឡូងដាំអីអញ្ចឹងទៅចិញ្ចិមខ្លួនឯង ដល់រួចគេមករើសទៀតហើយណា គេមករើសធ្វើទ័ពទៀតហើយ ។

ទេវិទ្ធ : ចិតប៉ុន្មានគេមករើសទ័ពទៀតហ្នឹង?

ឆោម : ឆ្នាំ៨៣ក្នុង៨៣ហ្នឹង ។

ទេវិទ្ធ : ៧៣?

ឆោម : អ៊ឺ ៧៣ ។

ទេវិទ្ធ : អ្នកណាគេមករើសហ្នឹងអ៊ំ?

ឆោម : ប្រធានមកពីខេត្តមក ។

ទេវិទ្ធ : ឈ្មោះអីគេអ៊ំ?

ឆោម : ខាងយោធាខេត្តឈ្មោះតាភា ប្រធានយោធាខេត្តណា ។

ទេវិទ្ធ : បាទ គេមកប្រាប់ថាម៉េចខ្លះ?

ឆោម : គេមកឲ្យរើសយោធា ។

ទេវិទ្ធ ៖ រើសយោធា?

ឆោម ៖ ហ្នឹងហើយ រើសហ្នឹងប្រធានមន្ទីក៏វាមានចិត្តធម៌ទៀតណាគេយកអាតាៗចាស់ៗហ្នឹង យកទៅលាក់នៅព្រៃភ្នំនោះ គេឲ្យទៅកាប់ព្រៃគេបញ្ជូនទៅកាប់ព្រៃនៅភ្នំនោះអស់ហើយ ហើយបើកូនក្មេងតូចៗគេឲ្យយកទៅ ហើយដល់តែពួកប្រធានបីខេត្តមកហ្នឹងគ្នាថាចុះម៉េច ឲ្យយកធំៗយកតូចៗអញ្ចឹងឲ្យគេ គេថាចុះបើគ្មានប៉ុនតែប្រធាននោះគេយកលាក់អស់ហើយ ។

ទេវិទ្ធ ៖ ចាស់ៗគេយកទៅកាប់ព្រៃអស់?

ឆោម ៖ អ៊ឺៗ!

ទេវិទ្ធ ៖ ចុះអ៊ំកាលហ្នឹងអ៊ំទៅជាមួយក្មេងៗ ទៅធ្វើទ័ព?

ឆោម ៖ ខ្ញុំ?

ទេវិទ្ធ ៖ បាទ!

ឆោម ៖ មិនទៅជាមួយក្មេងៗទេប៉ុន្តែវានៅជាមួយចាស់ៗនោះណា ដល់នេះអានោះកងសេដ្ឋកិច្ចជាមួយគ្នាហ្នឹងណាគេបញ្ជូនទៅទាំងអស់ ។

ទេវិទ្ធ ៖ អញ្ចឹងអ៊ំទៅកាប់ព្រៃដែរ?

ឆោម ៖ កាប់ព្រៃតែទាំងអស់គ្នាហ្នងទៅ ដល់តែពេលនេះកូនក្មេងអស់នោះហើយ ។

ទេវិទ្ធ ៖ កូនក្មេងអាយុប៉ុន្មាន?

ឆោម ៖ កូនក្មេងអាយុ១០ ១៥ឆ្នាំអីហ្នឹងកាលជនាន់ហ្នឹង ។

ទេវិទ្ធ ៖ ស្តាយកាំភ្លើងកើតដែរជប់ឆ្នាំ?

ឆោម ៖ ដឹងគេថាយកក្មេងៗមកឲ្យ បើប្រធានយោធាស្រុកនេះគេថាចុះបើគ្មាន ប៉ុនមិនដឹងថាគេយកអាធំៗទៅលាក់ទុកឯណា ។ វាមានដូចជាគេស្រោចស្រង់ម៉េចទេកាលខ្ញុំនៅជំនាន់ហ្នឹងមានគេមើលអញ្ចឹងទៅ ។

ទេវិទ្ធ ៖ ចុះទៅកាប់ព្រៃហ្នឹងយូទេអ៊ំ?

ឆោម ៖ ទៅកាប់ហ្នឹងវាដាំពោតដាំអីហ្នឹងណា ដាំពោតដាំដំឡូងអញ្ចឹងទៅ ។

ទេវិទ្ធ ៖ យូទេៗ?

ឆោម ៖ វារយៈពេលពីរបីមើលបិប្អូនខែហ្នឹងបើតាមមើល ។

ទេវិទ្ធ ៖ ហើយទៅណាទៀតទៅ?

ឆោម ៖ ដល់នេះគេស្រាវជ្រាវហើយគេមានឯកសារគេ គេសួរអ្នកណាមាននិន្នាការជំនាន់ហ្នឹងណាគេមាននិន្នាការហ៊ឺ ដល់កន្លែងរកអ្នកនិន្នាការហ្នឹងទៀតហើយដល់និន្នាការខ្ញុំនេះមានបងមួយ

គាត់ធ្វើទាហាន លន់ នល់ វាមានពាក់ព័ន្ធណា អញ្ចឹងគេថាអ្នកជាប់ជំពាក់គេបញ្ជូនទៅលើ ។

ទេវិទ្ធ : បញ្ជូនទៅលើទៅណាវិញ?

ឆោម : បញ្ជូនទៅលើទៅស្រុកត្រាំកក់ដដែល ។

ទេវិទ្ធ : ទៅត្រាំកក់វិញ?

ឆោម : ទៅត្រាំកក់ ។

ទេវិទ្ធ : ចុះបងអ៊ំហ្នឹងជាប់និន្នាការដែរបងហ្នឹងយ៉ាងម៉េចហើយ?

ឆោម : បងហ្នឹងស្លាប់ហើយ ។

ទេវិទ្ធ : គេយក?

ឆោម : គេយកទៅ២០៨គ្រូនចាញ់ស្លាប់ហើយគេវៃពេក ។

ទេវិទ្ធ : ឆ្នាំណាដែរគេយកទៅហ្នឹង?

ឆោម : កាលហ្នឹងជំនាន់បែកណាបែកភ្នំពេញ៧៥ហ្នឹងណា ។

ទេវិទ្ធ : ៧៥?

ឆោម : អ៊ុំហ្នឹងហើយ ។

ទេវិទ្ធ : អូ អញ្ចឹងនៅពេលដែលគេចាប់ផ្ដើមរកឃើញថាអ៊ំមាននិន្នាការនេះគឺក្រោយ៧៥ហើយ? អ៊ំនិយាយនេះមុន៧៥ ឬក្រោយ៧៥?

ឆោម : និយាយមុន ។

ទេវិទ្ធ : មុន៧៥ទេ?

ឆោម : បាទ!

ទេវិទ្ធ : គេដឹងថាយើងមានបងធ្វើទាហាន?

ឆោម : បងធ្វើទាហានអញ្ចឹងគេបញ្ជូនទៅនៅគេថា មន្ទីរសិង្ហានតំបន់ខេត្តតាកែវ ។

ទេវិទ្ធ : នៅឯណាវិញកាលហ្នឹង?

ឆោម : នៅហៅថាដំណាក់ស្នួលយើងជិតត្រពាំងអណ្ដើកនេះ ។

ទេវិទ្ធ : នៅត្រាំកក់ហ្នឹងមិនមែន?

ឆោម : អ៊ុំ ត្រាំកក់ជិត២០៨គេហៅ២០៥នៅហ្នឹងណា ។

ទេវិទ្ធ : បាទ ។

ឆោម : ជិត២០៨កន្លែងឈើយសឹកដែរ ។

ទេវិទ្ធ :	ឆ្អឹអីខ្លះកាលហ្នឹង ។

ឆោម :	កាលហ្នឹងគេពេលទៅដល់គេថាឥលូវ ប្រធានមន្ទីហ្នឹងគេថាបងប្អូនមកដល់ហើយឥលូវគេចែកឆៀតដីឲ្យហូប ។

ទេវិទ្ធ :	ឆៀតដី?

ឆោម :	ឆៀតដីអរហើយពុថាឆៀតដីគេនៅស្រុកលើស្មានថានៅព្រៃភ្នំមានឆៀតដី ដល់ហើយគេយកឡាំងគេមកបើកហក យកទៅផ្ទៃចបមួយៗម្នាក់លើកគល់ព្រៃចង់ងាប់ ។ (សើច) យ៉ឺគេប្រើហ្នឹងប្រើឲ្យងាប់ហើយបែបគេយកឆៀតដីមកឲ្យស៊ីយកផ្ទៃចបមក បបួលគ្នាសើចលាន់ហ្នឹងអ្នកពាក់ព័ន្ធ ខ្លាចងាប់ដែរណាពួកយើងអ្នកពាក់ព័ន្ធហ្នឹងខ្លាចងាប់ដែរណា ។

ទេវិទ្ធ :	អញ្ជឹង?

ឆោម :	អ៊ី!

ទេវិទ្ធ :	ឲ្យផ្ទៃចបយកទៅលីងគល់ព្រៃនៅឯណា?

ឆោម :	គល់ព្រៃនៅបៀតៗអាជម្រុំស្នាក់នៅហ្នឹង គាស់ព្រៃគាស់ដំបូកអីហ្នឹង ។

ទេវិទ្ធ :	នៅធ្វើហ្នឹងយូទេនៅលីងគល់ហ្នឹង?

ឆោម :	បានពីរឆ្នាំលើកគល់ហ្នឹង ។

ទេវិទ្ធ :	លើករហូតដល់ដាច់ហ្នុងហើយអញ្ជឹង?

ឆោម :	ហ្នឹងហើយ ។

ទេវិទ្ធ :	លើករហុតដល់៧៩ហើយអញ្ជឹង?

ឆោម :	ហ្នឹងហើយដល់៧៩ហ្នុង ។

ទេវិទ្ធ :	អញ្ជឹង?

ឆោម :	បានគេឲ្យមក ។

ទេវិទ្ធ :	គេឲ្យមកៗនៅណា?

ឆោម :	មកនៅកន្លែងស្រុកហ្នឹងដដែល ។

ទេវិទ្ធ :	នៅកន្លែងណាអញ្ចេះ?

ឆោម :	មកគេឲ្យចូលសេដ្ឋកិច្ចស្រុកវិញដដែល ។

ទេវិទ្ធ :	សេដ្ឋកិច្ចស្រុក នៅណាទីតាំងគេ?

ឆោម :	អ៊ី ទីតាំងគេស្រេចតែគេជូននៅឃុំនេះជូននៅឃុំនោះរកទីតាំងមិនឃើញទេ ។

ទេវិទ្ធ :	ចុះសេដ្ឋកិច្ចស្រុកមានគ្នាប៉ុន្មាននាក់?

ឆោម ៖ វាមានស្រីផងប្រុសផងកាលជំនាន់ហ្នឹង ស្រីក៏មានប្រុសក៏មានដែរចូលហាហើយទាំងស្រីទាំងប្រុសហ្នឹងនោះ ។

ទេវិទ្ធ ៖ ចូលកងហាមួយទៀត?

ឆោម ៖ កងហាអាហ្នឹងសេដឋកិច្ចស្រុកអាសម្រាប់យើងទៅធ្វើស្រែធ្វើអីហ្នឹងហើយ ។

ទេវិទ្ធ ៖ ចុះប៊ីណាគេមេកងកាលហ្នឹង?

ឆោម ៖ មេកងឈ្មោះតាណែត ។

ទេវិទ្ធ ៖ តាង៉ែត?

ឆោម ៖ តាណែត ។

ទេវិទ្ធ ៖ តាណែត?

ឆោម ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ តាណែតហ្នឹងនៅឯណាដែរអ៊ំឥលូវហ្នឹង?

ឆោម ៖ ស្លាប់ហើយ ។

ទេវិទ្ធ ៖ អញ្ចឹងហើយគាត់មេកង?

ឆោម ៖ អ៊ឺ មេកងហើយអនុតាភា ។

ទេវិទ្ធ ៖ តាភា អនុ?

ឆោម ៖ អ៊ឺ!

ទេវិទ្ធ ៖ តាភា ហ្នឹងនៅណែាឥលូវហ្នឹង?

ឆោម ៖ ស្លាប់ហើយ ។

ទេវិទ្ធ ៖ ស្លាប់ដែរ?

ឆោម ៖ អ៊ឺ ដល់ខាងសេដ្ឋកិច្ចតាដួន ។

ទេវិទ្ធ ៖ តាដួន?

ឆោម ៖ អ៊ឺ ប៉ុនតែស្លាប់អស់ហើយ ។

ទេវិទ្ធ ៖ ស្លាប់ទៀត?

ឆោម ៖ អ៊ឺស្លាប់ គ្មានអ្នកណានៅទេ ។

ទេវិទ្ធ ៖ បាទ! ហើយដល់ពេលកងអ៊ំហ្នឹងយ៉ាងម៉េចទៅធ្វើអីខ្លះ?

ឆោម ៖ កងខ្ញុំនៅតែធ្វើតែស្រែធ្វើអីហ្នឹង មកពីលើមកគេឲ្យត្រីងៀតដីរមែកហ្នឹងមកវិញគេនៅធ្វើស្រែហ្នឹងទៀតទៅ ។

ទេវិទ្ធ : ធ្វើស្រែនៅណាដែរទៅអ៊ំ?

ឆោម : ធ្វើស្រែហ្នឹងទៅទម្រាំដល់បែកភ្នំពេញទៅ ខ្ញុំនិយាយត្រឹមពេលបែកភ្នំពេញហ្នឹងបានគេថាបងប្អូនណាស្នើរអីស្នើរទៅណាបែកហើយឥលូវ ៗ អញ្ចឹងខ្ញុំស្នើរប្រពន្ធ ស្នើរប្រពន្ធហ្នឹងមិនមែនស្នើរយាយទីហ្នឹងទេស្នើរឯណានោះតែដល់ហើយគេរៀបចំឲ្យនៅនេះ ។

ទេវិទ្ធ : (សើច) មិនមែនស្នើរយាយទីហ្នឹងទេ?

ឆោម : គេយកយាយទីហ្នឹងមកឲ្យទៅស្នើរតំណាងសិក្សារនោះនៅដើងនោះ រួចដល់នេះគេយកយាយតីមកឲ្យទៅយកយាយទីហ្នឹងហ្នងទៅ ។

ទេវិទ្ធ : ចុះអ៊ំរៀបការឆ្នាំណាអ៊ំ?

ឆោម : ឆ្នាំ៧៥ហ្នឹងម្ដង ។

ទេវិទ្ធ : ក្រោយបែកភ្នំពេញប្រហែលប៉ុន្មានខែប៉ុន្មានថ្ងៃដែរ?

ឆោម : ប្រហែលមួយខែទេ ។

ទេវិទ្ធ : មួយខែ?

ឆោម : អ៊ឺ គេប្រកាសហើយហ្នឹងអ្នកណាចង់បានប្រពន្ធស្នើរទៅ គេថាអញ្ចឹង ។

ទេវិទ្ធ : បាទ! ចុះអ៊ំក៏ស្នើររៀបការប្រពន្ធហ្នឹងទៅអញ្ចឹង?

ឆោម : ការទៅស្មានថាបានប្រពន្ធគេថា ទៅដេកទៅនារីទៅដេកនោះទៅគាងឯងមកដេកនេះកន្លះខែបានជួបគ្នាម្ដង ។

ទេវិទ្ធ : ចុះកាលស្នើរហ្នឹងស្នើរពីណាគេ?

ឆោម : ស្នើរមេឃុំគេ មេឃុំគេទាក់ទងទៅស្រុក ស្រុកគេអ្នករៀបចំហើយតាមមើល ។

ទេវិទ្ធ : បាទ ចុះអ៊ំពេលរៀបការហ្នឹងប៉ុន្មានគូ?

ឆោម : ជំនាន់ខ្ញុំមួយយប់ហ្នឹងប៉ុន្មានប្រាំពីរគូ ។

ទេវិទ្ធ : យប់ស្មើរណាដែរ?

ឆោម : ម៉ោងប្រាំពីរយប់ដល់ម៉ោង១០អីហើយ ៗ គ្រាន់តែឡើងផ្ដាច់ដៃ ។

អ៊ំស្រី : ឡើងនិយាយទៅឡើងនិយាយម្នាក់ម្ដង ។

ទេវិទ្ធ : ឡើងនិយាយម៉េចទៅអ៊ំ?

ឆោម : លើងនិយាយផ្ដាច់ដៃថាយកគ្នាជាប្ដីប្រពន្ធអីហ្នឹង ។

ទេវិទ្ធ : ចាំទេអ៊ំកាលហ្នឹងនិយាយថាម៉េចខ្លះ?

ឆោម : ផ្ដាច់ដៃថាយកគ្នាអស់មួយជីវិតអញ្ចឹងទៅតែប៉ុណ្ណឹង ។

ទេវិទ្ធ :	ប៉ុណ្ណឹងហើយ?

ឆោម :	ប៉ុណ្ណឹងហើយស្រីក៏អញ្ចឹងប្រុសក៏អញ្ចឹង ។

ទេវិទ្ធ :	ហើយប្រាំបីរគូ?

ឆោម :	អ៊ឺ!

អ៊ំស្រី :	គេដាក់តែផ្ការលើតុអញ្ចឹងគេឲ្យយើងឡើងនិយាយម្នាក់ម្តង ។

ទេវិទ្ធ :	អញ្ចឹងហ្ន?

ឆោម :	ផ្តាច់ផ្តាយកគ្នាអស់មួយជិវិតអញ្ចឹងទៅណា ។

ទេវិទ្ធ :	បាទ ហើយដល់ពេលការហើយម៉េចទៀតទៅ?

ឆោម :	ការហើយគេឲ្យមកនោកងចល័តធ្វើការងារផ្សេងៗគ្នាហើយ ។

ទេវិទ្ធ :	អញ្ចឹង ចុះមីងនៅខាងណាវិញ?

អ៊ំស្រី :	វែកដីដឹបូក ។

ទេវិទ្ធ :	ចុះអ៊ំ?

ឆោម :	ខ្ញុំក៏នៅកងចល័តដែរ ។

ទេវិទ្ធ :	កងចល័តខាងណាវិញ?

ឆោម :	កងចល័តនៅខាងវត្តទម្លាប់នោះហៅវត្តអង្គៗ ។

ទេវិទ្ធ :	ធ្វើងីនៅហ្នឹង?

ឆោម :	ធ្វើស្រែប្រាំងជាន់ថ្មីងជាន់អី ។

ទេវិទ្ធ :	កងចល័តធ្វើស្រែហ្នង?

ឆោម :	ហ្នឹងហើយអ្នកមានគ្រួសារហើយណា ។

ទេវិទ្ធ :	បាទ ចុះបងអ៊ំគេចាប់ពីអង្កាល់?

ឆោម :	ចាប់កាលបែកភ្នំពេញហ្នឹងឆ្នាំ៧៥ ។

ទេវិទ្ធ :	បែកភ្លាមហ្នឹង?

ឆោម :	អ៊ឺ បែកគេចាប់យក កាល៧៥គេបញ្ជូនទៅលើ ។

ទេវិទ្ធ :	គេបញ្ជូនអ៊ំទៅណាវិញ?

ឆោម :	ខ្ញុំនិយាយហើយៗទៅកាប់គល់កាប់អីហ្នឹង ។

ទេវិទ្ធ :	អូ អញ្ចឹងដល់ពេលគេបញ្ជូនអ៊ំទៅលើហ្នឹងឯងទៅកាប់គាស់គល់កាប់ងីហ្នឹង ។

ឆោម :	អ៊ឺ កន្លែងផ្សេតដីរខ្ញុំនិយាយរឿងផ្សេតដីរម៉េចហ្នឹង ។

ទេវិទ្ធ ៖ គេចាប់បងអ៊ំពេលហ្នឹងឯង?

ឆោម ៖ គេចាប់៧៥ហ្នឹង ។

ទេវិទ្ធ ៖ ចុះបងអ៊ំហ្នឹងឈ្មោះអីគេដែលគេចាប់ហ្នឹង?

ឆោម ៖ ម៉ៅ ឆ៊ុំ ។

ទេវិទ្ធ ៖ ម៉ៅ ឆ៊ុំ ហើយពេលហ្នឹងគាត់អាយុប៉ុន្មាន?

ឆោម ៖ អាយុមើលកាលគត់ស្លាប់៦៣ ។

ទេវិទ្ធ ៖ អូ គាត់ចាស់ហើយហ្ន គាត់អន្តាល់?

ឆោម ៖ ស្លាប់ដប់ឆ្នាំមកហើយ ។

ទេវិទ្ធ ៖ អូ អញ្ចឹងកាលហ្នឹងអាចនៅក្មេងដែរ ។

ឆោម ៖ នៅក្មេងដែរ ។

ទេវិទ្ធ ៖ អញ្ចឹងគាត់អ៊ី ដល់ពេល គាត់ធ្លាប់ធ្វើប៉ូលិស ឬធ្លាប់ធ្វើទាហាន?

ឆោម ៖ ធ្វើទាហានឡូឡូដើរប្រៀពេញទឹកពេញដីឲ្យតែគេស្តាប់ហ្នឹងមានដែលទៅវ៉ៃគ្នាឯណា អាពតគេយកទៅវ៉ៃចោលចុះមកលើពី២០៤នោះ អាពតវាយកទៅវ៉ៃហើយ គេចងអញ្ចឹងណែ ។

ទេវិទ្ធ ៖ ឃើញទេ?

ឆោម ៖ ឃើញគេចងយកទៅវ៉ៃរវល់តែវ៉ៃអានោះអានេះរត់ភឹង អាបងខ្ញុំរត់រួចណារត់រួចទៅគ្នាខំណែខ្ញុំនិយាយអារឿងប្រវត្តិបងខ្ញុំ ទៅខំណែរត់គេចបាំងតាមបឹងហ្នឹងណាទៅដល់ឃើញកូនត្នោតមួយអារអាចំណាំងដៃហ្នឹងណា អាដាច់ទោរត់រួចអញ្ចឹងបានឆ្លងអាកន្លែងស្ពានទម្លាប់នោះកឆ្លងទៅដល់ទៅៗទៅដល់ស្រុកយួន បានទៅដល់ស្រុកយួនហើយចង់មកស្រុកខ្មែរវិញដល់ចង់មកស្រុកខ្មែរវិញសុំកប៉ាល់ហោះគេជិះ ពួកខៀវគឺអាហ្នឹងវាសម្បូរកន្ទុំរុយសុំជិះមកៗតាកែវ ហើយគេមិនឲ្យទេគេមិនឲ្យដឹងធ្វើម៉េចឃើញឡានហក់ឡើងឡានជិះ រករុញៗមិកើតរុញទម្លាក់មិនកើតចុះបាននៅតាកែវនេះមក ។ អាហ្នឹងជិនាន់គេយកទៅវ៉ៃចោលបានចេញពីតាកែវមកទៀត កាលហ្នឹងចេញមកគេចាប់ទៅ២០៤ ។

ទេវិទ្ធ ៖ គេចាប់ទៅទៀត?

ឆោម ៖ អ៊ឺ គេចាប់ទៅ២០៤អាគេចាប់ទៅវ៉ៃចោលនោះមួយវគ្គ គេចាប់ទៅ២០៤មួយវគ្គ ។

ទេវិទ្ធ ៖ បន្ទាយ២០៤ហ្នឹងនៅណាវិញអ៊ំ?

ឆោម ៖ ២០៤នៅហ្នឹងគេហៅមួយភាគនិរតីហ្នឹងមានតាកែវ កំពត កំពង់ស្ពឺវាបីខេត្តណា ។

ទេវិទ្ធ : បាទ!

ឆោម : ក្នុងទល់ដែលហ្នឹងទល់ដែនកំពត តាកែវ កំពង់ស្ពឺ ។

ទេវិទ្ធ : មន្ទីរហ្នឹងគេហៅអី ធំណាស់?

ឆោម : ត្រពាំងគួស ភ្នំព័ទ្ធជុំវិញអញ្ចឹងនេហមើលទៅគ្មានឃើញស្អីទេឃើញតែភ្នំ ។

ទេវិទ្ធ : គុកមែនអាហ្នឹង?

ឆោម : គុកៗសម្រាប់ដាក់ឈ្លើយសឹក ហើយខ្ញុំទៅឃើញហើមទាំងប្រុសទាំងស្រីខ្វហអត់មានសក់ ផងជ្រុះសក់អាលីង ។

ទេវិទ្ធ : ចុះអ៊ំទៅឆ្នាំណាទៅឃើញហ្នឹង?

ឆោម : ខ្ញុំទៅហ្នឹងជំនាន់ឆ្នាំ៧៣ កាលខ្ញុំទៅនៅ២០៥ហ្នឹងគេធ្វើនិរសាពីមន្ទីមកឲ្យខ្ញុំយកសំបុត្រទៅ សំបុត្រទៅ២០៨ហ្នឹង ប្រធានគេប្រើទៅ ។

ទេវិទ្ធ : ទៅឃើញ?

ឆោម : ទៅឃើញហើយអាជ្ញវសែងយកទៅកប់ហ្នឹងនិយាយពីសទ្ធិកមួយថ្ងៃៗ ។

ទេវិទ្ធ : គេសម្លាប់ ឬក៏ចាញ់ស្លាប់?

ឆោម : ចាញ់ស្លាប់វាទៅកន្លែងហ្នឹងចាញ់ហ្នឹងស្លាប់ដោយចាញ់ហ្នឹង ។

ទេវិទ្ធ : នៅត្រពាំងគួសហ្នឹង?

ឆោម : គេហៅត្រពាំងគួសមន្ទីរឈ្លើយសឹកមន្ទី២០៨ ។

ទេវិទ្ធ : អញ្ចឹងឈ្លើសឹកហ្នឹងមានន័យថាម៉េច អ្នកដែល?

ឆោម : ខ្ញុំហ្នឹងក៏បេះ២០៨ដែរ២០៥ហ្នឹង គេយកទៅឲ្យកាប់ព្រៃកាប់អីលើកភ្លឺលើកអីដូចតែគ្នា អញ្ចឹងទៅ ។

ទេវិទ្ធ : ឈ្លើយសឹកហ្នឹងមានន័យថាអ្នកដែលធ្លាប់ធ្វើទាហាន លន់ នល់?

ឆោម : ហ្នឹងហើយទាហានដូចជាបដិវត្តដូចជាគ្រូ ធ្វើជាអីជាអ្នកជំនាន់ពីសង្គមហ្នឹងដូចថាយើងធ្វើ ផ្នែកចេះផ្នែកជ្រៅជ្រះនឹងសុទ្ធតែគេបញ្ជូនទៅអស់ហើយ ។

ទេវិទ្ធ : តាំងពី៧៣ម្លេះ?

ឆោម : អ៊ឺ បញ្ជូនទៅ២០៨ហ្នឹងកាលហ្នឹងគេនិយាយពាក្យបញ្ជូនទៅលើៗ ។

ទេវិទ្ធ : អញ្ចឹងដល់ពេលបងប្អូនគេបញ្ជូនទៅហ្នឹងដែរ?

ឆោម : គេបញ្ជូនទៅហ្នឹង ។

ទេវិទ្ធ : គាត់នៅហ្នឹងដែរនៅបានយូទេ?

ឆោម ៖ នៅបានដឹងប៉ុន្មានទេភ្លេចហើយ ហើយខ្ញុំនៅធ្វើទ័ពនៅនេះគេថាអ៊ី បងឯងគេបញ្ជូនទៅ ហើយខ្ញុំមិនដឹងធ្វើម៉េចទេ ក្បាលអាណាសក់អាហ្នឹងហើយជំនាន់ហ្នឹងគេនិយាយអញ្ចឹង ។

ទេវិទ្ធ ៖ ដល់ពេលគាត់ទៅនៅហ្នឹងយូទេអ៊ំ គាត់មកវិញទេ?

ឆោម ៖ អត់ ។

ទេវិទ្ធ ៖ ប៉ុន្មានឆ្នាំបានមកវិញ?

ឆោម ៖ នៅប្រហែលជិតមួយឆ្នាំហ្នឹងបែក ។

ទេវិទ្ធ ៖ នៅរហូតបែកប៉ុល ពត ឬក៏?

ឆោម ៖ មិនបែកទេគេឲ្យមកមុននោះ ។

ទេវិទ្ធ ៖ គេដោះលែង?

ឆោម ៖ អ៊ឺ គេដោះឲ្យមកហ្នឹង ។

ទេវិទ្ធ ៖ ពេលគាត់មកភូមិស្រុកវិញគេអត់ចាប់ធ្វើបាបគាត់ទេ?

ឆោម ៖ អត់ទេលែងធ្វើបាបហើយ ធ្វើបាបអស់ចិត្តហើយថាយកទៅវៃចោលក៏យកធ្វើម៉េចក៏ធ្វើ ឆ្អែតហើយ ។

ទេវិទ្ធ ៖ ពេលគេប្រលែងគាត់មកវិញគេឲ្យគាត់ធ្វើអីដែរ?

ឆោម ៖ ឲ្យធ្វើប្រជាជនយើងធម្មតាហ្នឹង ។

ទេវិទ្ធ ៖ នៅណាអ៊ំនៅណា?

ឆោម ៖ នៅក្នុងភូមិហ្នឹងភូមិមិនជាមួយគ្នាទេភូមិខុសគ្នា ហើយឥលូវនៅតែប្រពន្ធកូន ។

ទេវិទ្ធ ៖ បាទ! ចុះយើងអ៊ំម្តងដល់ពេលអ៊ំទៅធ្វើស្រែនៅទម្លាប់ហ្នឹងទៅ ហើយយ៉ាងម៉េចទៀតទៅ ធ្វើយូទេ? ធ្វើស្រែទម្លាប់កងចល័តហ្នឹង?

ឆោម ៖ កងចល័តហ្នឹងខ្ញុំនៅបានមួយឆ្នាំ ។

ទេវិទ្ធ ៖ នៅមួយឆ្នាំណែ?

ឆោម ៖ ហ្នឹងហើយ នៅមួយឆ្នាំទៅហើយ គេដកខ្ញុំមកវិញហើយ ។

ទេវិទ្ធ ៖ ដកទៅណាវិញ?

ឆោម ៖ ដកមកចុលទ័ពស្រុកហ្នឹងអាដែលៗវិលចុះវិលឡើងមកធ្វើអាទ័ពស្រុកហ្នឹងវិញអាដែល ។

ទេវិទ្ធ ៖ ទ័ពស្រុក?

ឆោម ៖ ទ័ពស្រុកហ្នឹងបានរត់យួនហើយ ។

អ៊ំស្រី ៖ ជិតចប់ហើយ ។

ទេវិទ្ធ : អូ ៧០ប៉ុន្មានដែរបានមកដល់ទ័ពស្រុកវិញ?

អ៊ំស្រី : កាលហ្នឹងកូនកើតមួយហើយបង ។

ឆោម : អូ ៧៧កូនកើតមួយហើយហ្នឹង ដល់ទៅទ័ពស្រុកហ្នឹង អាហ្នឹងដល់កន្លែងរត់យួនហើយហ្នឹង ។

ទេវិទ្ធ : ដល់ពេលអញ្ចឹងទីតាំងទ័ពអ៊ំនៅណាទ័ពស្រុកហ្នឹង?

ឆោម : ទ័ពខ្ញុំនៅវត្តអង្គក្រឡឹង ទ័ពស្រុកប៉ុនមិនដែលទៅវ៉ៃគេទេ ។

ទេវិទ្ធ : ពីណាគេប្រធានអ៊ំ?

ឆោម : តាណាម ។

ទេវិទ្ធ : តាណាម?

ឆោម : តាណាម ។

ទេវិទ្ធ : តាណាមហ្នឹងនៅណាសព្វថ្ងៃ?

ឆោម : តាណាមហ្នឹងប្ដីយាយយឿន យាយយឿនហ្នឹងគេផ្លាស់ចុះម្ចាស់ស្រុកផ្លាស់ទៅវិញទៅមកធ្លាប់ជាម្ចាស់ស្រុកម្ដង ។

ទេវិទ្ធ : អូ គាត់ជាគណៈស្រុក?

ឆោម : គណៈស្រុកម្ដងគណៈស្រុកជំនួសប្ដីម្ដងព្រោះប្ដីគាត់កាន់ខាងយោធា ។

ទេវិទ្ធ : ប្ដីយោធាប្រពន្ធគណៈស្រុក?

ឆោម : អ៊ឺៗគណៈស្រុក ។

ទេវិទ្ធ : អូ អញ្ចឹងប្រធានអ៊ំតាណាមហ្នឹងហើយ?

ឆោម : តាណាម ប្រធានក្រោយហ្នឹងណាក្រោយមកទៀតរត់យួនហើយ ចប់ហើយដល់កន្លែងរួចខ្លួនហើយខ្ទេចខ្ទីអស់ហើយ អស់ហើយប្រវត្តិខ្ញុំអស់ហើយតែប៉ុណ្ណឹងចប់ហើយ ។

ទេវិទ្ធ : ខ្ញុំនៅសួរអ៊ំតិចទៀត?

ឆោម : សួរអីទៀតបើអស់ហើយ ។

អ៊ំស្រី : ចប់កន្លែងរត់ហ្នឹងហើយ ។

ទេវិទ្ធ : អញ្ចេះអ៊ំគណៈស្រុកមុនដំបូងគេពីណាគេ?

ឆោម : កនៈស្រុកពីដំបុងគេតាណែម តាតុំ ។

ទេវិទ្ធ : តាណែម តាតុំ?

ឆោម : ហ្នឹងហើយ ពួកនោះតាំងពីកាលដែលអង្គការខ្មែរបង្កើតអង្គការខ្មែរមកហើយនោះណា ។

ទេវិទ្ធ : បាទៗ!

ឆោម : ជំនាន់នោះអកណាទៅជាមួយវៀតណាមជាមួយយៀកកុងឲ្យចេញមក មកចុលអន្តការខ្មែរ វិញហ្នឹងឈ្មោះតាគុំ ។

ទេវិទ្ធ : បាទ ពេលឆ្នាំ៧៩ណាអ៊ំ? ពេលបែកភ្នំពេញមកពេលប៉ុលពតឈ្នះណា ឈ្នះលន់ នល់ ហ្នឹងអ្នកណាលើកគនៈស្រុកគិរីវង្ស?

ឆោម : គណៈស្រុកគិរីវង្សហ្នឹងវាប៉ុន្មានជំណរនោះមើលចេញពីតាគុំមក យាយបូរ យាយបូរស្រី ទៀតហ្នឹងហើយគណៈស្រុក ។

ទេវិទ្ធ : ហើយក្រោយមកពីណាទៀត?

ឆោម : ក្រោយមកទៀតមានយាយយឿនហ្នឹង ។

ទេវិទ្ធ : យាយយឿន?

ឆោម : វាបីបន្លាស់ហ្នឹងណា ។

ទេវិទ្ធ : ហើយក្រោយមកទៀត?

ឆោម : ក្រោយមកទៀតអស់ហើយ ។

ទេវិទ្ធ : ចុះតាទិនហ្នឹងអ្នកណាគេ?

ឆោម : តាទិនហ្នឹងណែគាត់ខាងមន្ទីគាត់កាន់ខាងក្រសួងមន្ទី គាត់អត់ធ្វើគណៈស្រុកគណៈអីទេគាត់ ហ្នឹង ។

ទេវិទ្ធ : និយាយទៅគណៈស្រុកមានបីនាក់?

ឆោម : ហ្នឹងហើយ ។

ទេវិទ្ធ : ហើយអញ្ចឹងក្រៅពីយាយបូរហ្នឹងមានពីណាទៀត ព្រោះមានអ្នកខ្លះកាន់ខាងយោធាអ្នកខ្លះ កាន់ខាងអ៊ឺមន្ទី អ្នកខ្លះកាន់ខាងសេដ្ឋកិច្ចអញ្ចឹងណែ?

ឆោម : វាមានដកខ្លះវាមានមិនដកខ្លះជំនាន់ហ្នឹងវា ខ្ញុំនិយាយវំលងដែរមានតាហាណូយនោះមក ធ្លាប់មកនៅស្រុកយើងនេះមានពីរនាក់ តាហាណូយៗហ្នឹងថាទៅធ្វើស្រុកលើតែមាន បីសាឡេហ្នឹងចេញមថាតាហាណូយៗហ្នឹងណា ។

ទេវិទ្ធ : ពីណាគេយាហាណូយហ្នឹង?

ឆោម : មួយឈ្មោអះតាឈិន មួយឈ្មោះតាមី ប៉ុនគេយកទៅសម្លាប់ចោលផស់ហើយខ្មែរក្រ ហមយកទៅសម្លាប់ចោល ។

ទេវិទ្ធ : គាត់មកពីឆ្នាំណាបានធ្វើគណៈស្រុកកាលហ្នឹង?

ឆោម ៖ គាត់មកជិនាន់អង្គការខ្មែរបង្កើតហ្នឹង មិនបានធ្វើទេគ្រាន់តែគេទុកនៅមួយឡែកអញ្ចឹងណា ចាំមើលគេមើលឯងមិនបានធ្វើមុខងារអីទេតាហ្នឹង ។

ទេវិទ្ធ ៖ ខ្មែរតើអីគាត់ហ្នឹង?

ឆោម ៖ ខ្មែរ ។

ទេវិទ្ធ ៖ តែមកពីហាណូយ?

ឆោម ៖ មកពីហាណូយ ។

ទេវិទ្ធ ៖ ហើយគេហៅខ្មែរហាណូយ?

ឆោម ៖ អ៊ឺ គេហៅតាហាណូយហើយចេះភាសាវៀតណាមច្រើនណាស់ ចេះទាំងអស់ ។

ទេវិទ្ធ ៖ បាទ!

ឆោម ៖ អាតាឈ្មោះហាណូយហ្នឹងវាសម្លាប់ចោលអស់ហើយ ។

ទេវិទ្ធ ៖ សម្លាប់ឆ្នាំណា?

ឆោម ៖ សម្លាប់ជំនាន់អីនេះជំនាន់ គេសម្លាប់ចោលអស់ហើយគេមិនទុកទេឃើញមកសុទ្ធតែមានបឹសសាឡៅដែរ ។

ទេវិទ្ធ ៖ បឹសសាឡៅហ្នឹងអីគេអ៊ំ?

ឆោម ៖ បឹសសាឡៅហ្នឹងឡើងថ្ងៃហ្នឹងហើយ ។

ទេវិទ្ធ ៖ បឹសសាឡៅ បាទ អ៊ំអញ្ចឹង អ៊ឺ តាទិតហ្នឹងគាត់កាន់ខាងគណៈស្រុកជាមួយយាយបូរតាំងពី៧៥មកមែនទេ?

ឆោម ៖ មុន ។

ទេវិទ្ធ ៖ មុន៧៥ទៀត?

ឆោម ៖ ៧៥យាយឃឿន ។

ទេវិទ្ធ ៖ ៧៥យាយឃឿន?

អ៊ំស្រី ៖ មិនមែនទេ

ឆោម ៖ មុនៗគាត់កាលចុះមកពីលើ

អ៊ំស្រី ៖ យាយឃឿនក្រោយគេទេ

ឆោម ៖ អ៊ឺ អញ្ចឹងបាន៧៥ហ្នឹងបែក៧៥ហ្នឹងយាយឃឿន

អ៊ំស្រី ៖ ដល់រត់ទៅឡើហ្នឹងយាយហ្នឹងកាន់កាប់ដល់នេះបែកគ្នាអញ្ចឹងទៅ ។

ទេវិទ្ធ ៖ ចុះតាទិតហ្នឹងគាត់កាន់ពីឆ្នាំណាដល់ឆ្នាំណាដែរ?

អុំស្រី : តាទិតអីចាញ់តាគុំនោះទេតាគុំ ប្រធានអញ្ចឹងទេឪ?

ឆោម : តាទិតគាត់ប្រធានមន្ទីរ ។

ទេវិទ្ធ : គណៈស្រុក១០៩?

ឆោម : គណៈស្រុកដែរប៉ុនកាន់ខាងមន្ទីរគាត់ដូចជាទទួលភ្ញៀវទទួលអីអញ្ចឹងណា មានអ្នកមកពីខេត្ត មកពីអីហ្នឹងនៅលើគាត់ ។

ទេវិទ្ធ : ចុះអ្នកកាន់ទ័ពកាលហ្នឹងឆ្នាំណាពីណាគេ?

ឆោម : កាន់ទ័ពកាលជំនាន់ហ្នឹងមានតែតាណែមហ្នឹង ។

ទេវិទ្ធ : តាណែម? ឆ្នាំណាហើយអុំនិយាយនេះ?

ឆោម : កាលហ្នឹងឆ្នាំ៧៣ ។

ទេវិទ្ធ : ដល់ឆ្នាំណា?

ឆោម : គាត់កាន់មកដល់ឆ្នាំ៧៣ហ្នឹងគាត់កាន់មកដល់៧៨ស្រាប់តែគេផ្លាស់ទៅទៀតទៅ ។

ទេវិទ្ធ : ពីណាម្តង?

ឆោម : ពីណាទេកាលហ្នឹងឈ្មោះគេស្អីទេភ្លេចហើយ តាណែមហ្នឹងក៏ត្រូវគេយកទៅវ៉ៃចោលដែរ គេយកទៅវ៉ៃធ្វើបាបគេដកចោលដូចកូនស្តែអញ្ចឹង ។

ទេវិទ្ធ : បាទ!

ឆោម : តាណាមហ្នឹងមកហើយឆ្នាំ៧៨ហ្នឹង ។

ទេវិទ្ធ : តាណាម?

ឆោម : អ៊ឺ មកគាត់មកជាមួយប្រពន្ធគាត់ ។

ទេវិទ្ធ : តាណាមហើយពីណាទៀតទៅ?

ឆោម : អស់ហើយចប់ហើយ ។

ទេវិទ្ធ : តាណាម ក្រែងយាយយឿនក៏អីចុងក្រោយគេ?

ឆោម : អ៊ឺ តាណាម យាយយឿន ប្តីប្រពន្ធគាត់ហ្នឹង ។

ទេវិទ្ធ : អូ តាណាម យាយយឿនហ្នឹង?

ឆោម : អ៊ឺ!

ទេវិទ្ធ : ចុះតាទិតហ្នឹងគាត់ទៅណាវិញ?

ឆោម : តាទិត ហ្នឹងបាត់ខ្លួនថាទៅលើៗបាត់រហូតទៅ ។

ទេវិទ្ធ : គេដកគាត់កាន់តំណែងខាងលើ?

ឆោម ៖ គេយកតាទិតហ្នឹងមានបងប្អូនធ្វើការខាងរដ្ឋកម្ពុជា ដឹងយ៉ាងម៉េចខ្ញុំអត់នៅទេដឹងម៉េចទៅ ។

ទេវិទ្ធ ៖ ចុះប្រធានតំបន់កាលហ្នឹងពីណាគេអ៊ំ នៅ៧៥ ?

ឆោម ៖ ប្រធានតំបន់មានតែតាសោម និងតាមុតអត់មានដូរទេ ។

ទេវិទ្ធ ៖ តាមុត ត្រកូលគាត់អីគេ?

ឆោម ៖ ខ្ញុំមិនដឹងឈ្មោះអីទេត្រកូលឈ្មោះអីទេដឹងតែ តាមុត តាសោម ហ្នឹង ។

ទេវិទ្ធ ៖ តាសោមពីណាគេតាសោមហ្នឹង?

ឆោម ៖ តាសោម ហ្នឹងគាត់កាន់ខាងយោធា តាមុត កាន់ខាងខេត្តគណៈតំបន់អីហ្នឹងអនុៗបន្ទាប់ពីតាភា ។

ទេវិទ្ធ ៖ តាភា ចុះបីនាក់ហ្នឹងសព្វថ្ងៃនៅឯណាដែរ?

ឆោម ៖ គ្មាននៅទេ ដឹងនៅឯណាទេស្លាប់បាត់អស់ហើយដឹងអាណាទៅណាអាណាទៅណីទេ កាលនោះគេសុទ្ធតែអាយុបងយើងហើយយើងចំណាស់នេះទៅហើយគេម៉េចនឹងនៅ ។

ទេវិទ្ធ ៖ អ៊ំនិយាយពីគុកវិញម្តងមើល គុកតាមភូមិយើងមានទេ?

ឆោម ៖ អត់មានទេ ។

ទេវិទ្ធ ៖ គុកឃុំ?

ឆោម ៖ មានតែសាលាស្រុក ។

ទេវិទ្ធ ៖ សាលាស្រុក សន្តិសុខស្រុក? សន្តិសុខស្រុកឈ្មោះសន្តិសុខអីគេ?

ឆោម ៖ សន្តិសុខស្រុក ឬក៏អ្នកកាន់មន្ទីនគរបាល?

ទេវិទ្ធ ៖ មន្ទីនគរបាលហ្នឹងហើយ?

ឆោម ៖ មន្ទីនគរបាលឈ្មោះព្រីងៗ ។

ទេវិទ្ធ ៖ នៅឯណាទីតាំងគេ?

ឆោម ៖ ទីតាំងទីលំនៅគេនៅវត្តប្រធាតុហ្នឹង ទៅមើលក្បាលទៅនៅច្រងោៗនោះ ។

ទេវិទ្ធ ៖ នៅវត្តប្រធាតុហ្នឹង?

ឆោម ៖ វត្តប្រធាតុហ្នឹងគេតាំងក្នុងហ្នឹង ។

ទេវិទ្ធ ៖ ប្រធានឈ្មោះអីគេអ៊ំ?

ឆោម ៖ ប្រធានឈ្មោះវា តាព្រីង ។

ទេវិទ្ធ ៖ តាព្រីង ត្រកូលគាត់ត្រកូលអីគេ?

ឆោម ៖ ខ្ញុំមិស្គាល់ទេស្គាល់តែឪ ។

ទេវិទ្ធ :	ឪឈ្មោះអីគេ?

ឆោម :	ហម ព្រីង ។

ទេវិទ្ធ :	អញ្ចងឪឈ្មោះហម ហើយ?

ឆោម :	អ៊ឺ!

ទេវិទ្ធ :	អញ្ចឹងគាត់ ហម ព្រីង?

ឆោម :	ហ្នឹងហើយ ។

ទេវិទ្ធ :	ចុះគាត់នៅឯណាដែរ?

ឆោម :	នៅវត្តហ្នឹងគេវ៉ៃចោលបាត់តៅហើយ ។

ទេវិទ្ធ :	វ៉ៃចោលហើយ ចុះប្រពន្ធគ្រួសារគាត់នៅណា?

ឆោម :	គ្មានទេប្រពន្ធក៏គ្មានដែរបាត់ទាំងអស់ហ្នឹង ។

ទេវិទ្ធ :	ផ្ទះនៅគិរីវង្សហ្នឹងស្រុកកំណើត ។

ឆោម :	អូ ស្រុកកំណើតនៅហ្នឹងទេហ្ន?

ស៊ុយហៀង :	គេវ៉ៃគាត់ចោលឆ្នាំណាលោកអ៊ំ?

អ៊ំស្រី :	វ៉ៃពេលរត់ទៅលើហ្នឹង ។

ឆោម :	កាចពេកអញ្ចឹងហើយ ។

ស៊ុយហៀង :	ខ្មែរក្រហមអ្នកវ៉ៃ ឬក៏ប្រជាជន?

អ៊ំស្រី :	ប្រជាជនហ្នឹង ។

ទេវិទ្ធ :	ពេលវៀតណាមចូលហ្នឹង?

ឆោម :	អ៊ឺ ហើយទៅហ្នុងកន្លែងហ្នឹងទៅឃើញហើយវាមានផ្ទកវានៅតាំងនៅហ្នឹង គេធ្វើកន្លែងឲ្យស្អាតណាស់ ។

ទេវិទ្ធ :	ទៅឃើញហើយអ៊ំអស់ឆ្អឹងហើយហ្នឹង?

ឆោម :	នៅៗឆ្អឹង ក្បាល ។

ទេវិទ្ធ :	ក្បាលសល់តែពីរបីខ្ញុំទៅមូរិលមិញ ។

ឆោម :	អ៊ឺ នៅតែប៉ុណ្ណឹងកាលពី២០ជាងនោះក្មេងវាលេងហើយបាត់ ឬក៏ឆ្កែពាំឬកម៉េចទេនៅសល់ប៉ុណ្ណឹងគេទុកជាភស្តុតាងបើកាលនេះច្រើន ។

ទេវិទ្ធ :	អ៊ំដែលបានទៅឃើញមន្ទីហ្នឹងទេក្នុងសម័យនោះណា?

ឆោម ៖ ខ្ញុំអត់បានទៅទេកាលហ្នឹងគេរៀបបញ្ជូនទៅហើយប៉ុនខ្លះមិនឲ្យខ្ញុំទៅ គេថាខ្ញុំមកផ្ទះលឿន ពេកតែតិចៗលួចមកផ្ទះហើយតាំងពីមានប្រពន្ធមក គេថាតិចពិបាកចូលនគរបាល នគរអី នគរទៅតែត្រូវទៅផ្ទះទៅហើយអត់មានការអី ។

ទេវិទ្ធ ៖ ចុហគុកតំបន់នៅឯណា?

ឆោម ៖ គុកតំបន់អត់ដឹងនៅឯណាទេដឹងតែនៅវត្តប្រធាតុមួយកន្លែងហ្នឹង ។

ទេវិទ្ធ ៖ ចុះនៅតាមឃុំអីអត់មានទេហ្ន?

ឆោម ៖ គ្មានទេតាមឃុំអត់មានទេ ។

ទេវិទ្ធ ៖ តាមសហករណ៍អីក៏អត់ដែរ?

ឆោម ៖ គ្មានទេ ។

ទេវិទ្ធ ៖ អញ្ចឹងម៉ាស្រុក១០៩នេះអ្នកដែលខុសអ្នកដែលត្រូវចាប់ខ្លួនអីបញ្ជូនទៅណា?

ឆោម ៖ ទៅតែមួយកន្លែងហ្នឹង គេចាប់ដាក់ខ្នោះកងជើងមួយជួរអញ្ចឹងទៅ គេរាប់មួយពីបីគេរុញ បុកអ្នកណាគេចមិនទាន់ត្រូវទៅ ។

អ៊ំស្រី ៖ កាលពីជំនាន់ហ្នឹងថាវាយ៉ាប់ ។

ឆោម ៖ អញ្ចឹងវាបើតាមការផ្សារហ្នឹងតាមមើលខ្ញុំក៏វាចាំមិននេះដែរ បើនិយាយទៅវាច្រើនភ្លេចខ្លះ អីខ្លះទៅវាដុំៗ ។

ទេវិទ្ធ ៖ អញ្ចឹងនិយាយរឿងអំធ្វើនិរសាគេវិញម្តង ធ្វើនិរសាធ្លាប់ធ្វើនិរសាឲ្យអ្នកណាខ្លះ?

ឆោម ៖ ធ្វើនិរសាឲ្យតែយាយបូរហ្នឹង ធ្វើនិរសាគេហ្នឹងបានតែប៉ុន្នានថ្ងៃដកទៅនៅឯណាពេញទឹក ពេញដី ។

ទេវិទ្ធ ៖ ចាប់ផ្តើមធ្វើនិរសាគាត់ហ្នឹងឆ្នាំណា?

ឆោម ៖ ធ្វើចាំមើលពីដូចជា៧៨អីហ្នឹងហើយមើលទៅ ។

ទេវិទ្ធ ៖ ចុងក្រោយនេះហ្នឹង?

ឆោម ៖ អត់ទេដូចជាឆ្នាំ៧០ក៏អី? របបខ្មែរក្រហមប្រាំឆ្នាំអី?

ទេវិទ្ធ ៖ របបខ្មែរក្រហមតែ៧៥ដល់៧៩តើ ៣ឆ្នាំជាង ។

ឆោម ៖ អ៊ឺ!

ទេវិទ្ធ ៖ ភ្លេចហើយ?

ឆោម ៖ ហ្នឹងហើយ ។

ទេវិទ្ធ ៖ តែដឹងថាធ្វើនិរសាឲ្យយាយបូរ?

ឆោម : ធ្វើតែវាមិនបានវែង ។

ទេវិទ្ធ : ចុះអ៊ំនាំសំបុត្រទៅណាខ្លះ?

ឆោម : នាំសំបុត្រឲ្យឃុំហ្នឹង ដូចថាយើងបររទេះសេះបរអីទៅគេផ្ញើរតាមមកនោះណា មិនមែន និរសារអីដើរតាមគេទេ ។

ទេវិទ្ធ : ផ្ញើរមកឲ្យឃុំហ្នឹងឃុំពីណាគេ?

ឆោម : ឃុំណាក៏ផ្ញើរដែរចេះតែទៅហើយឃុំព្រែកអណ្ដើកស្អីៗចេះតែទេហើយ ព្រោះយើងអ្នកដើរអ្នកមានរទេះសេះបើថ្ងៃណាយើងមិនទៅត្រូវផ្លូវទេគេមិនរកយើងទេ ។

ទេវិទ្ធ : អត់ដែលហានលួចបើកមើលទេ?

ឆោម : អត់ទេ តែគេដឹងគេវ៉ៃ ។

ទេវិទ្ធ : យកឲ្យប្រធានសហករណ៍ហ្នឹងមិនមែនទេ?

ឆោម : យកមកឲ្យឃុំហើយមិនដឹងគេចាត់ទៅណាទៀត ។

ទេវិទ្ធ : អញ្ចឹង?

ឆោម : អ៊ឺ! ឃុំគេមានអ្នកក្ដោបក្ដាប់តាមភូមិទៀត ។

ទេវិទ្ធ : អត់មានដែលយកទៅឲ្យខាងសន្ដិសុខខាងអីទេ?

ឆោម : អត់ទេប្រគលល់ឲ្យតែឃុំហ្នឹង ។

ទេវិទ្ធ : ចុះអ៊ំនៅតាមកងរបស់អ៊ំអីហូបឆ្អែតទេ?

ឆោម : អូ និយាយរឿងហូបកមុនិយាយបបរបីស្លាបព្រានោះ ខ្ញុំមិនស្រួលលួចអាសម្បកដូងគេកាប់ហើយយកមកអាំងស៊ីហើយបើមានគេដឹកពោតដឹកអីមកអញ្ចឹងទៅ ណែដុតហ្នឹងអត់ហានឲ្យផ្សះទេកប់អាភ្នក់យើងហ្នឹងឲ្យជិតដល់ផ្សះមិនព្រុទេអាហ្នឹងណា ផ្សះអត់ព្រុទេចេះណាស់ដុតពោតដុតមិនឲ្យព្រុទេ ។ កាលជំនាន់ហ្នឹងដុតពស់ដុតអីតាមវាលស្រែក្ដាមអីហ្នឹងអាក្ដាមយើងហ្នឹងទៅលើកភ្លឺស្រែលើកអីតែឃើញចាប់លាត់ក្នុងចង្កេះយកទៅស៊ីទាំងរស់ ។

ទេវិទ្ធ : ស៊ីទាំងរស់?

ឆោម : ស៊ីទាំងរស់ហ្នងហើយអាតូចៗទំពារក្រូបៗហើយខ្លាចគេឃើញទៀតណា ស៊ីហ្នឹងមិនឲ្យគេឃើញតែគេឃើញគេហៅគោផលូវហ្នឹងគេយកមកណែនាំ ។

ទេវិទ្ធ : តែអ៊ំកាលហ្នឹងក្រែងនេះអ៊ំអីមកពីយើងអ្នមូលដ្ឋានដងទេបានគេមិនថាអី?

ឆោម : ហ្នឹងហើយអ្នកមូលដ្ឋានបើអ្នកថ្មីហានតែធ្វើអីអញ្ចឹងអត់បានទេ គេយកទៅភ្លាមអត់មានបានស៊ីក្ដាមអីទេ ។

ទេវិទ្ធ : ចុះនៅក្នុងកងរបស់អ៊ឹកងហា ពេលធ្វើនិរសាក្តីអីក្តីហ្នឹងមានអ្នកថ្មីទៅជាមួយទេ?

ឆោម : អត់

ទេវិទ្ធ : អត់មានទេ?

ឆោម : មានកាលខ្ញុំនៅកងចល័តមានអ្នក១៧នៅជាមួយដែរ ។

ទេវិទ្ធ : អញ្ចឹង?

ឆោម : អ៊ឺ ហើយបើខាងយុវជននោះក៏មានអ្នក១៧នៅជាមួយដែរ ខ្ញុំដើរឲ្យត្រពាសហ្នឹងដួនមកនៅធ្វើយុវជនអញ្ចឹងទៅដើរទៅនោះទៅ អញ្ចឹងបានខ្ញុំថាខ្ញុំដើរត្រពាសចេះតែរស់ដែរហ្នងណា ។ ជំនាន់ហ្នឹងគ្មានបានទៅវ៉ៃទៅតប់អីឲ្យធំដុំអីអត់ទេ ទៅបានតែចូលសមរភូមិចេហតែបាននៅរស់ដែរ ចេះអែបអបគេ ។

ទេវិទ្ធ : ចេះអែបអបគេអីណែ អែបអបពីណាគេ?

ឆោម : និយាយពីរឿងការងារខ្ញុំតែធ្វើអីស្អាតណាស់ ដឹកប្រឡាយលើកភ្លឺស្រែអីបានឲ្យតែល្អចេះអែបអបអារឿងការងារហ្នឹង អែបអបពីរឿងវាយការបីនោះពីនោះអីខ្ញុំមិនដែលទេចេះតែឲ្យតែរស់តែខ្លួនឯងទេ ។

ទេវិទ្ធ : គិតតែប្រឹងធ្វើការ?

ឆោម : ធ្វើការឲ្យគេតែឲ្យស្អាតទៅណាគេមិនយកយើទៅណាទេ គេស្រលាញ់យើងធ្វើការស្អាតយកចិត្តទុកដាក់គេរឿងការងារ ហើយយើងធ្វើការអញ្ចឹងគេចូលចិត្តណាស់កេថាធ្វើស្អីស្អាតហ្នឹង ។

ទេវិទ្ធ : អ៊ឺដែលឃើញគេចងមនុស្សចងអីទេដឹកនឹងសេះដឹកអីអញ្ចឹងដែលឃើញទេគេវ៉ៃមនុស្សវ៉ៃអី?

ឆោម : អូ អារឿងហ្នឹងឃើញពេកហើយ ម៉េចមិនឃើញថាមិនឃើញវាដូចជាកុហក ។

ទេវិទ្ធ : ឃើញញឹកហ្នងហើយ?

ឆោម : ឃើញបើអារឿងវ៉ៃមិនដែលទេ ។

ទេវិទ្ធ : ឃើញគេចង?

ឆោម : អ៊ឺ បើគេចងគេដឹកអីអាហ្នឹងដែលឃើញ ។

ទេវិទ្ធ : ឃើញនៅណាអ៊ឺ?

ឆោម : ឃើញយកគៅព្រៃកប្រធាតុឃើញអីមិនដែលដឹងទេហ្នឹងដឹងយកទៅវ៉ៃចោលនៅណាទេ ប៉ុនតែរឿងចងឃើញហើយដាក់សាលាឃុំដាក់ច្រវ៉ាក់ដាក់អីទម្រាំគេបញ្ជូនទៅ ។

ទេវិទ្ធ :	ភាគច្រើនអ្នកណា អ្នកថ្មី ឬក៏អ្នកអីគេ?

ឆោម :	អាអ្នកថ្មីក៏មានអ្នកចាស់ក៏មានវាលាយគ្នាហ្នឹងជំនាន់ហ្នឹង មិនថាអ្នកចាស់អ្នកថ្មីទេតែយើងខុសសូម្បីតែម៉ែឪវា អ្នកឯងថ្មីចាស់អី ។

អុំស្រី :	សុទ្ធតែលបស្តាប់ដេកយប់ឡើង ហានតែយើងនិយាយមិនស្រួលវាយកទៅ ។

ទេវិទ្ធ :	ដែលឃើញនៅសាលាឃុំអុំណែ? សាលាស្រុកដែលឃើញទេ?

ឆោម :	សាលាស្រុកមិនដែលទេមានត្រឹមឃុំវាយកពីឃុំហ្នឹងទៅបាត់ហើយ មនដឹងទៅឯណាទៀតទេ ។េ

ទេវិទ្ធ :	គេមានបញ្ជូនទៅស្រុកសិនអីអត់ទេ?

ឆោម :	អត់ទេ ។

ទេវិទ្ធ :	ចេញតែពីឃុំទៅៗ?

ឆោម :	ដឹងទៅណាបាត់ទៅហើយអាគ្នាវាអ្នកចងអ្នកអីហ្នឹងវាចេះតែថាយកទៅលើៗ ដឹងទៅលើឯណាគ្មានទេទៅលើៗ ។

ទេវិទ្ធ :	យាយបូរប្រធានអុំហ្នឹងមនុស្សម៉េចដែរអុំ?

អុំស្រី :	គាត់មិនចេះវៃចេះអីទេ គាត់ស្រីហើយចាស់ហើយហ្នឹង ។

ឆោម :	អាយុប៉ុន្មានហើយ?

ទេវិទ្ធ :	៥០ ៦០ហើយអី ។

ឆោម :	គាត់មនុស្សម៉េចដែរកាច ស្លូត?

ទេវិទ្ធ :	គាត់មិសូវអីប៉ុន្មានទេ ។

ឆោម :	មិនសូវអិអញ្ចឹងមានន័យថាកាចដែរ?

ទេវិទ្ធ :	អ៊ឺ!

ឆោម :	មិនអីតែយើងអាក្នុងខ្លួនគេអាណាដឹង គេអ្នកស៊ីញ៉ៅគេស្រុកគេកាន់ស្រុក ។

ទេវិទ្ធ :	ស៊ីញ៉ៅអីគេអុំ? និយាយទៅអ្នកស៊ីញ៉ៅចាប់មនុស្សចាប់អីហ្នឹងអ្នកណាគេទៅហ្ន?

ឆោម :	មេស្រុកហ្នឹងហើយស៊ីញ៉ៅទាល់តែមេស្រុកស៊ីញ៉ៅបានគេហានសម្លាប់ ។

ទេវិទ្ធ :	អត់ទេ និយាយនេះស្មានទេ ឬមួយក៏ឃើញមែន?

ឆោម :	មិនស្មានទេនិយាយមែន ។

ទេវិទ្ធ :	អញ្ចឹងគណៈស្រុក្នកស៊ីញ៉ៅ? មើលអុំនិយាយមើលមុនដំបូងអ្នកណាផ្នកចាប់ផ្តើមពីភូមិពីឃុំទៅឬក៏យ៉ាងម៉េច?

ឆោម ៖ មេស្រុកគេអ្នកស៊ីញ៉ោមុន ។

ទេវិទ្ធ ៖ តែឈ្មោះអស់ហ្នឹងគេបានមកពីខាងណា បានពីឃុំពីអី?

ឆោម ៖ អ៊ឺ ទៅដល់គេថាគេស៊ីញ៉ោហើយអស់ហើយ មេឃុំគេទៅចាត់ការទៅ ។

ទេវិទ្ធ ៖ ស្រុកមានឈ្លបទេអ៊ំ?

ឆោម ៖ ស្រុកគេមានប្រចាំនៅកងស្រុកគេ អាវ៉ែៗ អាប្រចាំនៅកន្លែងស្អីនិន្នាការស៊ើបរកគេ ។

ទេវិទ្ធ ៖ អញ្ចឹង អ៊ំដែលឃើញគាត់ស៊ីញ៉ោឲ្យចាប់អីទេ?

ឆោម ៖ មិនដែលទេ ។

ទេវិទ្ធ ៖ ចុះម៉េចបានអ៊ំដឹងស្រុកអ្នកស៊ីញ៉ោ?

ឆោម ៖ ចុះបើពួគេថាជំនាន់ហ្នឹងពួគេនិយាយ ។

ទេវិទ្ធ ៖ ពួពីណាគេនិយាយអ៊ំ?

ឆោម ៖ គេទាហានអ្នកប្រជាពលរដ្ឋទាំងអស់គ្នាគេថាតែស្រុកស៊ីញ៉ោឲ្យហើយៗហើយ ។

ទេវិទ្ធ ៖ អញ្ចឹងពួគេមនិយាយទេអ៊ំ?

ឆោម ៖ អ៊ឺ ពួគេនិយាយតើតែស្រុកស៊ីញ៉ោចប់ហើយ ។

ទេវិទ្ធ ៖ ស្រុកស៊ីញ៉ោ?

ឆោម ៖ អ៊ឺ ភូមិ ឃុំ គេចាត់ការហើយ បានរស់មកហើយនេះអ្នករស់ពីជំនាន់ ប៉ុល ពត ដូចបានមានមួយល្អីអញ្ចឹង ។

ទេវិទ្ធ ៖ បានរស់?

ឆោម ៖ ប្រាប់សជព្វថ្ងៃក្មេងៗឥលូវវាមិនជឿទេយើងប្រាប់គេមិនជឿទេ ដល់អ្នកដឹងអាក្បាលជន្តធំធំជាងបានដឹង (សម្លេងខ្យល់) ទាល់តែគល់ប្ញស្សីត្បូងចបបានវាស្លាប់ ត្រឹមតែដូចជំនាន់នេះឥលូវអញ្ចឹងនេះ ។

ទេវិទ្ធ ៖ ហៀងមានអីសួរអ៊ំទេ?

ស៊ុយហៀង ៖ ចុះបច្ចុប្បន្នអ៊ំធ្វើការអីដែរ?

ឆោម ៖ ចប់ហើយខ្ញុំនិយាយស្អីច្រើនពេកទេវាជាន់គ្នាដដែលៗ ។

ហៀង ៖ រាល់ថ្ងៃធ្វើអីដែរអ៊ំ?

ឆោម ៖ រាល់ថ្ងៃធ្វើស្រែហ្នឹង ។

ទេវិទ្ធ ៖ កសិករអ៊ំហ្ន?

ឆោម ៖ ហ្នឹងហើយកសិករចំហើយរាល់ថ្ងៃនេះគ្មានធ្វើស្អីទេ ។

ទេវិទ្ធ : ស្រែច្រើនទេអ៊ំ?

ឆោម : ស្រែពីរហិចតាហ្នឹង ។

ទេវិទ្ធ : ពីរហិចតា?

ឆោម : អ៊ុ!

ទេវិទ្ធ : ធ្វើបានទេអ៊ំឥលូវស្រែ?

ឆោម : ធ្វើបានតើមានអី ។

ទេវិទ្ធ : អត់ខ្វះទឹកខ្វះអីទេ?

ឆោម : ទឹកមិនខ្វះទេមានគ្រប់គ្រាន់ហើយពីមុនខ្វះឥលូវមានហើយ ។

ទេវិទ្ធ : ក្រែងតាកែវពីមុនសំបូរស្រែកថាខ្វះទឹកណា?

ឆោម : និយាយពីស្រូវឥលូវវាល្អទៅមើលក្រោមនោះ ។

អ៊ំស្រី : តាហ្នឹងគាត់ប្រធានឃុំដែរប្រធានឃុំក្នុងឃុំយើងរាល់ថ្ងៃហ្នឹងណា ។

ទេវិទ្ធ : បាទ!

ឆោម : អ៊ុ ជំនាន់ចុះមកពីហ្នឹងជំនាន់បែកហ្នឹងគេឲ្យធ្វើតាំងពីអ៊ុយគេមក ។

ទេវិទ្ធ : ដល់ឥលូវហ្នឹង?

ឆោម : អ៊ុ! គេឲ្យធ្វើដំណើរជនរបូតគេឲ្យធ្វើសាលាជនរបូតដល់មក ។

ទេវិទ្ធ : សាលាជនភូមិ?

ឆោម : សាលាជនឃុំ ។

ទេវិទ្ធ : ឃុំ? អីយ៉ាឃុំតើ ។

ឆោម : ហ៊ុ កាលហ្នឹងវៃខ្មែរក្រហមជាមួយខ្មែរក្រហមទៀតនោះណា ។ ទើបឈប់ពេលចាស់នេះហើយមានកូនមានចៅឲ្យធ្វើប្រធានឃុំ (សម្ដេងខ្យល) នៅសល់ពី នោះមក គេអាណិតគេមិនប្រើទៀតណាគេមិនឲ្យទៅកប្រាំទៅអីឯណា រួចខ្លួនរបូតហ្នឹង ។

ទេវិទ្ធ : អ៊ំចុះពេលវៀតណាមចូលមក ខ្ញុំភ្លេចសួរកន្លែងនេះបន្តិច ពេលវៀតណាមចូលមកអា៧៩ ណាពេលវៀតណាមវៃចូលណាអ៊ំនៅណាកាលហ្នឹង?

អ៊ំស្រី : នៅហ្នឹង ។

ទេវិទ្ធ : នៅហ្នឹងទាំងអស់គ្នា?

អ៊ំស្រី : គ្មានទេណាទេ ។

ទេវិទ្ធ : ដល់ពេលវៃមកហ្នឹងយ៉ាងម៉េចទៅ?

ឆោម ៖ នាំគ្នារត់ ។

ទេវិទ្ធ ៖ រត់ទៅណាវិញ?

ឆោម ៖ រត់ទៅលើនោះ ។

ទេវិទ្ធ ៖ លើខាងណា?

ឆោម ៖ ទៅលើបរទេសបរអី ។

អ៊ំស្រី ៖ ទៅស្រុកលើហើយដល់តែគេចេះតែទៅលើយើងមក្រោមវិញមក ។

ទេវិទ្ធ ៖ លើៗទៅខាងណាលើហ្នឹង?

ឆោម ៖ ទៅស្តុកហៅវត្តស្តុកវត្តអី ។

ទេវិទ្ធ ៖ ស្តុកហ្នឹងខាងណាវិញ?

ឆោម ៖ ស្តុកនៅឯលិចហ្នឹងខាងលើរត់ទៅលើៗហ្នឹង ។

ទេវិទ្ធ ៖ អត់ដឹងទេអញ្ចឹង?

ឆោម ៖ អ៊ឺ!

ទេវិទ្ធ ៖ កាលទៅយូទេបានត្រលប់មកវិញ?

ឆោម ៖ យ៉ឺ អាខ្លះនៅយូ ។

ទេវិទ្ធ ៖ ចុះអ៊ំៗផ្ទាល់?

ឆោម ៖ វិលមកវិញ ។

ទេវិទ្ធ ៖ ប៉ុន្មានថ្ងៃមកវិញ?

អ៊ំស្រី ៖ ដល់កោះស្ទីត្រពាំងអណ្តើកដល់ត្រពាំងអណ្តើកមកវិញ ។

ទេវិទ្ធ ៖ ប៉ុន្មានថ្ងៃដែរកាលហ្នឹង?

អ៊ំស្រី ៖ គៅប្រហែលកន្លះខែ មកដល់យួននៅពេញហ្នឹងនេះយួនមកនៅពេញហ្នឹងហើយមកដល់ជញ្ជូនស្រូវជញ្ជូនអីដាក់ទុកស៊ីនឹងគេទៅពេញដីស្រូវ ។

ទេវិទ្ធ ៖ ហើយរស់នៅអញ្ចឹងរហូតទៅ?

អ៊ំស្រី ៖ រហូតទើសឥលូវ ។

ទេវិទ្ធ ៖ ខ្មែរក្រហមមានខស្សាហ៍វៃឆ្មក់ចូលទេក្នុងឆ្នាំ៨០អី?

ឆោម ៖ ឆ្មក់ចូលដែរនៅគោកព្រែកកាពែន ។

ទេវិទ្ធ ៖ គោកព្រែកកាពែននៅខាងណាវិញ?

អ៊ំស្រី ៖ នៅខាងលិច ។

ទេវិទ្ធ : អញ្ចឹង ខ្ញុំអត់មានអីសួរអ៊ំទៀតផង ។

ឆោម : ខ្ញុំក៏អត់ដឹងនិយាយម៉េចដែរនិយាយទៅវាជាន់លើអានិយាយដដែលៗហ្នឹង និយាយៗវាវ៉ាយរ៉ាប់តែពីរឿងពីដើមមក ដល់ថ្នាក់កូនក្តាមស៊ីទាំងឆៅហើយ ដុតពស់ ដុតអីស៊ី បន្លយថ្ងៃអីប៉ុន្មានចាប់មកអាំង ។

ទេវិទ្ធ : ក្តាមឆៅទៀតណាអ៊ំនិយាយមិញក្តាមឆៅ?

ឆោម : ក្តាមឆៅពស់ក្រឡាប់កន្ត្រប ពស់ព្រលិតអីហ្នឹង ស៊ីលួចស៊ីខ្លាចគេឃើញទៀតណាលាងដៃលាងអីឲ្យជ្រះទៀតណា ម្យ៉ាងខ្លាចគេមកហិតដៃហិតមាត់អីធំខ្ទិនយើង ហើយបបរនោះទៀត ស្លឹកម្រុំលួចទៅបោចខ្លាចគេឃើញទៀតយកមកលាយជាមួយឲ្យវាបានច្រើនបន្តិច ។

ទេវិទ្ធ : អញ្ចឹង?

ឆោម : បើនិយាយទៅវាចេះតែមានអញ្ចឹងណា សម្បកដូងហ្នឹងគេបកហើយយកមកអាំង ពោតអីលួចបានដុតៗមិឲ្យពួសួរទេកប់ផេះឯងឲ្យជ្រៅខ្លាចវាផ្ទុះ អត់ឲ្យឬសួរទេដល់នេហលួចប្រលេះស៊ី ។

ទេវិទ្ធ : អ៊ំអញ្ចឹងអរគុណច្រើនណាអ៊ំណា អស់សំនួរអីហើយ ។

ឆោម : អ៊ឺ ហើយហូបបាយហូបទឹកអីណាកូន?

ទេវិទ្ធ : អត់ទាន់ដឹងចាំជុំគ្នាមកមិញពីរបីឡាន ។

ឆោម : អញ្ចឹង?

ទេវិទ្ធ : បាទ!

អ៊ំស្រី : ហើយផ្ទះនៅភ្នំពេញហ្នង?

ទេវិទ្ធ : បាទ! បាទ អញ្ចឹងអរគុណច្រើនណាអ៊ំណា ។

ឆោម : អ៊ឺ យើងនិយាយរឿងប្រវត្តិហ្នឹងវាអញ្ចឹងហើយឆ្នកដឹងបានដឹងឆ្នកមិនដឹងក៏មិដឹងនិយាយម៉េចដែរសម័យនោះ ។

ទេវិទ្ធ : បាទ!

ឆោម : ព្រោះយើងវាបានឆ្លងកាត់ ។

អ៊ំស្រី : គាគាត់នៅចងចាំខ្ញុំវិញភ្លេចអស់ហើយ ។

ទេវិទ្ធ : មានកន្លែងណាដែលអ៊ំចាំហើយខ្ញុំមិនទាន់បានសួរទេ?

ឆោម : មិនឆាយនឹកចាំអស់ទេ ។

ទេវិទ្ធ : បាទ! បាទ អញ្ចឹងខ្ញុំអរគុណច្រើនណាអ៊ំណា ។

ឆោម :     ហ៊ឹងហើយ ។

ទេវិទ្ធ :     បាទៗ !

**ចប់**